# អារម្ភកថា

៙

កំរងអត្ថបទកំណាព្យនេះ ប្រសូត្រចេញពីឧបនិស្ស័យនៃកុសលចិត្ត ជាអ្នកស្រឡាញ់ គោរពជឿជាក់ក្នុងព្រះពុទ្ធសាសនាផង កើតពីការអប់រំប្រៀន-ប្រដៅរបស់មាតាបិតាខ្ញុំផង កើតពីការស្តាប់ព្រះធម៌-ទេសនា និងការទទួលឱវាទប្រៀនប្រដៅអំពីលោកម្ចាស់គ្រូ ព្រះភិក្ខុវជិរប្បញ្ញោ **សាន សុជា** និងលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស** ផង ។

ខ្ញុំព្រះអង្គម្ចាស់ ខ្ញុំព្រះករុណា នាងខ្ញុំ សូមគោរពលើកទូលជានិច្ចនូវព្រះគុណដ៏ធ្ងន់ របស់ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ជីវិតតម្កល់លើត្បូង គុណមាតាបិតាខ្ញុំ គុណព្រះអង្គគ្រូ និងគុណលោកគ្រូ សព្វៗកាល ។ សូមព្រះពុទ្ធវច្ចនៈដែលជាអរិយមរតក ដ៏កំរក្រៃនឹងកើតមានឡើង

ក្នុងលោក បានសណ្ឋិតជាប់ក្នុងដួងចិត្តពុទ្ធបរិស័ទទាំងឡាយសព្វទិនទិវារាត្រីដោយសារធម្មទានដ៏តូចនេះ ។

សូមការអាន និងការស្តាប់ព្រះធម៌ដោយគោរព បានជាបច្ច័យនាំលោកអ្នកពុទ្ធបរិស័ទ ទាំងអស់ កាន់តែមានបញ្ញាជាសម្មាទិដ្ឋិ ចាក់ធ្លុះត្រាស់ដឹងនូវអរិយសច្ចធម៌ទាំងបួនប្រការ នាអនាគតកាល កុំបីឃ្លាងឃ្លាតឡើយ ។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែវិសាខ ឆ្នាំមមែ សប្តស័ក ពុទ្ធសករាជ ២៥៥៩ ត្រូវនឹងថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០១៥ ទីក្រុងមែលប៊ិន ប្រទេសអូស្ត្រាលី ។

# សេចក្តីថ្លែងអំណរព្រះគុណ

ពុទ្ធបរិស័ទទាំងឡាយ រួមនិងខ្ញុំព្រះករុណាផ្ទាល់ សូមក្រាបថ្វាយបង្គំអរព្រះគុណព្រះអង្គយ៉ាងក្រៃលែង៖

១.ព្រះភិក្ខុវជិរប្បញ្ញោ **សាន សុជា** ដែលបាន ផ្តួចផ្តើមបង្កើតវិបសាយធម្មទាននេះឡើង ។

២.ព្រះភិក្ខុនិស្សយកទ្ធោ **តេ វិចិត្រ** ដែលបាន រចនារៀបចំទំព័រវិបសាយនេះឲ្យកាន់តែល្អប្រពៃឡើង ដើម្បីជាការងាយស្រួលដល់សិក្ខាកាមជនទាំងឡាយ ដែលចង់រៀនសូត្រយល់ដឹងអំពីព្រះពុទ្ធវចនៈ ដែលព្រះធម្មកថិកច្រើនអង្គ មានលោកម្ចាស់គ្រូ **សាន សុជា** ជាដើមបាន សំដែងទុក មកតាមគម្ពីរដីការបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។ ម៉្យាងទៀតខ្ញុំព្រះករុណាក៏សូមថ្លែងអំណរព្រះគុណជាអនេកប្បការ ផងដែរចំពោះលោកម្ចាស់ **តេ វិចិត្រ** ដែលព្រះអង្គមានព្រះទ័យអនុគ្រោះ ឆ្លៀតពេល

ពីការសិក្សាដ៏មមាញឹក មកជួយរៀបចំបញ្ចូលកំរងកំណាព្យដែលខ្ញុំព្រះករុណាបានរៀបរៀងហើយ ទៅក្នុងវិបសាយនោះទៀត ។ តាមបុណ្យកុសលដែលព្រះអង្គតែងព្យាយាមសន្សំមកមិនដាច់នេះ សូមព្រះតេជគុណទាំងពីរព្រះអង្គបានកើតជាអ្នកមានបញ្ញាមុតស្រួច និងបានចាក់ធ្លុះត្រាស់ដឹងនូវអរិយសច្ចធម៌ទាំងបួន នាអនាគតកាលកុំបីអាក់ខានឡើយ ។ ខ្ញុំព្រះករុណាសូមត្រេកអរជ្រះថ្លាអនុមោទនាផងដែរនូវមហាបុណ្យធម្មទាន អំពីព្រះតេជគុណទាំងពីរ ព្រះអង្គសព្វៗ កាល !!! ។

សូមព្រះគុណម្ចាស់ទាំងពីរព្រះអង្គ មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំព្រះករុណា ។

ឧបាសិកា **ឱម លក្ខណា**

# មាតិកា ទំព័រ

១. មិនគួរប្រកាន់ចិត្តជារបស់ខ្លួន...................... ០១
២. ព្រះសម្មាសម្ពុទ្ធជាគ្រូពេទ្យ......................... ០៣
៣. កុំជាប់ចិត្តក្នុងរសអាហារ........................... ០៦
៤. ប្រយ័ត្នត្រូវអាននុរិយកម្ម ដោយមិនដឹងខ្លួន..... ០៩
៥. សូមកុំភ្លេចធាតុដើម.................................. ១២
៦. ភ្នែកពីរគង់ខុសគ្នា...................................... ១៤
៧. អ្នកយាមទ្វារចិត្ត........................................ ១៥
៨. ចិត្តនិងចេតសិកជាសម្បយុត្តធម៌................. ១៧
៩. របស់អនត្តា................................................ ១៨
១០.មិនគួរយកធម៌ធ្វើជាខ្លួន............................. ១៩
១១.របស់ក្តៅ.................................................... ២០
១២.កុំស្តាយភ្លើងធាតុ....................................... ២១
១៣.កុំសេពគប់នឹងទោសៈ................................ ២២
១៤.កំណាព្យខ្លីៗ.............................................. ២៤
១៥.ជឿកម្មផលទើបឈប់ទោមនស្ស.................. ២៤
១៦.សុខទុក្ខជាផលរបស់កម្ម.......................... ២៥

១៧.ធម៌គួរយល់ដឹង........................................ ២៦
១៨.ថម្គុះក៏ជាអកុសល.................................... ២៧
១៩.គ្រូពេទ្យក្អកមាន់...................................... ២៨
២០.សុខដោយនេក្ខមៈទើបគ្រប់........................ ២៨
២១.ត្រូវពិនិត្យឲ្យច្បាស់មុនសេពគប់................... ២៩
២២.កុំទុកចិត្តសញ្ញា....................................... ២៩
២៣.ជួយតែខ្លួនឯងសិនចុះ................................៣០
២៤.ពាក្យរោយរាយនាំធ្លាក់នរក.........................៣១
២៥.កុំកើតទុក្ខនឹងកិលេសគេ...............................៣១
២៦.លាងចិត្តយើងមុន......................................៣២
២៧.កុំផ្តាប់ផ្តុនលោភៈ.......................................៣៣
២៨.លោកនេះជាទ្រុងមច្ចុរាជ.............................៣៤
២៩.អកុសលកម្មទេដែលត្រូវវៀរ........................ ៣៥
៣០.សូមកុំបានធ្លាប់ដូចគេ................................. ៣៦
៣១.ប្រយ័ត្នកម្មកត់.......................................... ៣៦
៣២.ចាញ់គេចុះតែឈ្នះខ្លួនឯង.......................  ៣៧
៣៣.ភ្នែកកើតព្រោះបុណ្យ គួរទុកធ្វើតែកម្មល្អ.........៣៧

៣៤.ចិត្តអើយចិត្ត........................................ ៣៨
៣៥.សំដី.................................................... ៤១
៣៦.សតិជាថ្នាំ............................................... ៤១
៣៧.ស្រះទឹក................................................. ៤២
៣៨.បំណុលកាម.............................................. ៤៣
៣៩.អប់រំចិត្ត................................................. ៤៤
៤០.ដំណើរធម្មយាត្រាទៅស្រីលង្កា.................... ៤៦
៤១.បើអត់ខឹងទើបអត់ខុស................................ ៥២
៤២.រង្កៀសកិលេសខ្លួនឯងវិញ.......................... ៥៣
៤៣.កុំជាប់ចិត្តកុំចង់បានសង្ខារធម៌...................... ៥៤
៤៤.គុណរបស់សទ្ធា....................................... ៥៥
៤៥.កុំខ្មាសគ្រូពេទ្យ......................................... ៥៦
៤៦.ម៉ែត្រេកអរនឹងកូនសាងផ្នួស........................ ៥៧
៤៧.ត្រូវជួយខ្លួនដោយខ្លួនឯង.......................... ៥៩
៤៨.នឹកស្រុកព្រះណាស់....................................៦០
៤៩.ព្រះគុណម្ចាស់ជាបុរសផ្កាយ........................៦៣

៥០.តាមហេតុបច្ច័យចុះ.................................... ៦៤
៥១.រឿងពិតរបស់ជីវិត........................................ ៦៤
៥២.ផ្លូវនៃសេចក្តីសុខ........................................ ៦៦
៥៣.ព្រះទ័យព្រះអគ្គសាវ័ក................................ ៦៧
៥៤.បើចង់ឲ្យគ្រប់ត្រូវឈប់ចង់............................ ៦៨
៥៥.ឈ្នះខ្លួនឯងទើបប្រសើរ.............................. ៦៩
៥៦.បរិជិណ្ណមិទំ រូបំ............................................ ៦៩
៥៧.កុំសេពគប់នឹងសាបេយ្យៈ............................ ៧១
៥៨.ចិត្តយើងចិត្តគេ............................................ ៧២
៥៩.អត់ធន់ ៣ ប្រការ.......................................... ៧២
៦០.រលកលោកធម៌............................................ ៧៣
៦១.ធម៌គួរពិចារណា ៨ យ៉ាង.............................. ៧៤
៦២.អ្វីដែលគួរខ្លាចពិតប្រាកដ............................ ៧៧
៦៣.តុលាការត្បាញអាយ.................................... ៧៨
៦៤.សត្វលោកខុសគ្នាដោយធម៌.......................... ៧៨
៦៥.ហេតុតែរបស់ខ្ចីគេ.......................................... ៧៩
៦៦.គួរឲ្យទានតែរបស់ល្អ.................................... ៧៩

៦៧.កុំកាន់ជើងខ្លួនឯង.................................... ៨០
៦៨.ការផ្សេងគ្នារវាងបុថុជ្ជននិងអរិយបុគ្គល.......... ៨១
៦៩.មហាភូតរូប ៤ ក៏ដូចជាដុំពពុះទឹក................ ៨២
៧០.តម្រាផ្សំធាតុ............................................៨៣
៧១.វិយោគកថា..............................................៨៤
៧២.ថាមិនមែនរូបដដែលទេ!.............................៨៨
៧៣.ព្រះនាងរោហិណីសរសើរគុណព្រះសង្ឃ....... ៨៩
៧៤.អ្នកសូមទានមិនមែនជាភិក្ខុទេ..................... ៩២
៧៥.អកុសលចិត្តខ្លះត្រូវផ្តាច់ដោយវិធីណា?..........៩៣
៧៦.គួរត្រាប់អ្នកប្រាជ្ញ....................................... ៩៥
៧៧.ព្រះពុទ្ធោវាទចំពោះកូនគោឃាតកៈ.............. ៩៥
៧៨.ព្រះពុទ្ធោវាទប្រារព្ធនូវកុលបុត្រម្នាក់............. ៩៧
៧៩.ព្រះពុទ្ធោវាទប្រារព្ធនូវមេណ្ឌកសេដ្ឋី.............. ៩៨
៨០.ឈ្មោះនៃកុសលធម៌...................................៩៩
៨១.កុំចង់កែ.................................................. ១០០
៨២.ខុសគ្នាជានិច្ច...........................................១០០
៨៣.បណ្តាំម្តាយ...............................................១០១

៨៤.កុំចង់ចំណេញ........................................... ១០២
៨៥.ទោសនៃលោភៈទោសៈមោហៈ.................... ១០២
៨៦.គុណនៃសតិប្បដ្ឋាន..................................... ១០៤
៨៧.ព្រហ្មចរិយធម៌ជាថ្នាំ.................................... ១០៥
៨៨.ផែនដីមិនលំអៀង........................................ ១០៦
៨៩.ស្គាយពុកណាស់.......................................... ១០៧
៩០.ព្រៃគោសិង្គសាលវ័នរុងរឿងដោយសារភិក្ខុ..... ១០៩
៩១.ន័យនៃការបាចលាច................................... ១២០
៩២.គុណមាតាបិតា........................................... ១២២

# ១. មិនគួរប្រកាន់ចិត្តជារបស់ខ្លួន

៙ កុំមានព្រះពុទ្ធត្រាស់ដោយល្អ
ម្ល៉េះមនុស្សនិករនៅយល់ខុស
មិនឃើញចិត្តបាបថាជាទោស
ស្វាគមន៍ទោមនស្សគ្រប់ខណៈ ។
៙ អកុសលកើតច្រើនជាងកុសល
រាល់ថ្ងៃច្របល់ដោយមោហៈ
លោករាប់ចំនួនចិត្តទោសៈ
តិចជាងលោភៈអភិជ្ឈា ។
៙ នៅពេលករុណាអ្នកដទៃ
ជាបុណ្យប្រពៃល្អមហិមា
តែត្រូវពិនិត្យចិត្តវេទនា
តើមានអវិជ្ជាចូលរួមដែរ ? ។
៙ បើផែកទៅឃើញព្រួយយំសោក
ស្រណោះស្រណោកក៏គួរតែ

ដឹងថាអកុសលបួលមចូលក្បែរ

មិនមែនមានតែកុសលទេ ។

ឈ អ្នកខ្លះយល់ខុសពីការពិត

ថាករុណាចិត្តនុះទាល់តែ

ស្រពោនអាក់អន់ជួយខឹងជេរ

ជាមួយនឹងគេទើបហៅស្មោះ ។

ឈ តែការយល់ត្រូវគឺករុណា

ត្រឹមជាឧបេក្ខាឬសោមនស្ស

គ្មានទុក្ខសោកសៅគ្មានទោមនស្ស

ទើបលោកឲ្យឈ្មោះករុណាពិត ។

ឈ ទោមនស្សវេទនាគ្មានទីពឹង

កើតរួមតែនឹងទោសៈ ចិត្ត

ផ្សំឡើងដោយហេតុបច្ច័យល្អិត

មិនគួរប្រកាន់ចិត្តជារបស់ខ្លួន ។

# ២.ព្រះសម្មាសម្ពុទ្ធជាគ្រូពេទ្យ

៙ យប់មួយត្រជាក់ខែរនោច

ព្រះច័ន្ទនៅតូចរះព្រាងៗ

ជួនភ្លឺជួនល្ងឹតប្រែមិនទៀង

ពពកមុនភ្លៀងបាំងច័ន្ទបាត់ ។

៙ ភ្លៀងធ្លាក់រន្ទះភ្លឺម្តងៗ

សូរផ្គរឆ្លើយឆ្លងទាំងយប់ស្ងាត់

មែកស្រល់អោរាំដោយខ្យល់ផាត់

អ្នកភូមិលក់បាត់ក្នុងនិទ្រា ។

៙ ខ្ញុំបើកបង្អួចសម្លឹងមេឃ

ចិត្តនឹកសង្វេគយើងគ្រប់គ្នា

កើតមកត្រូវជួបចាស់ជរា

ថែមទាំងរោគាតាមប្រល័យ ។

៚ សង្វេគនឹងស្លាប់ដូចគល់ឱស

កំពុងនៅរស់ប្រែក្សិណក្ស័យ

សង្វេគសត្វលោកខ្លាចទុក្ខភ័យ

ប៉ុន្តែគ្មានអ្វីអាចជួយបាន ។

៚ សង្វេគម្យ៉ាងទៀតនឹងអ្នកក្រ

រស់ទាំងត្រដររមិនសុខសាន្ត

សង្វេគអ្នកមានខ្លះក៏បាន

ទុក្ខសោករំខានប្រហែលគ្នា ។

៚ ជីវិតជាទុក្ខព្រោះមិនទៀង

រាំងធ្លាក់ដូចភ្លៀងគ្រប់វេលា

ផ្លាស់ខ្មើត រនោចដូចចន្ទ្រា

ជួនឃោលឃោរាដូចចុងស្រល់ ។

៚ ដួងខែគង់តែពពកបាំង

ជួនផ្គរលាន់ខ្លាំងដោយមេខ្យល់

សត្វលោកងុយងោកក្នុងកម្មផល

គប្បីស្វែងយល់រសធម្មា ។

✍ ព្រះធម៌មានគុណយ៉ាងសក្តិសិទ្ធ

ព្យាបាលរោគចិត្តឲ្យបានជា

ព្រះពុទ្ធជាគ្រូពេទ្យសួគ៌ា

ពួកយើងរាល់គ្នាជាអ្នកឈឺ ។

# ៣.កុំជាប់ចិត្តក្នុងរសអាហារ

៙ ព្រះពុទ្ធជាម្ចាស់ប្រៀបឧបមា
កវលិង្ការាហារមានន័យ
ដូចជាភរិយានិងស្វាមី
បីទាំងកូនខ្ចីដើរផ្លូវឆ្ងាយ ។
៙ ផ្លូវកន្តារៈកើតទុរភិក្ស
ព្រោះខ្វះបាយទឹកផ្គត់ផ្គង់កាយ
មានចោរសត្វកាចនាំអន្តរាយ
អមនុស្សទាំងឡាយបៀតបៀនផង ។
៙ ដើរយូរស្បៀងតិចដាច់អាហារ
គិតគ្នាប្រហារកូនតែម្តង
យកសាច់បរិភោគដើម្បីឆ្លង
វាលធំកន្លងជាផ្លូវឆ្ងាយ ។
៙ ពេលលេបសាច់កូនពិចារណា
មិនមែនជាការលេងសប្បាយ

មិនមែនសម្រាប់តាក់តែងកាយ
ជាប់ចិត្តរីករាយក្នុងការឆី ។
៚ ពីព្រោះជាសាច់កូនបង្កើត
ជាទីស្រឡាញ់ពេញហឫទ័យ
សាច់នោះនៅឆៅហើយទន់ខ្ចី
គ្មានរសជាតិប្រៃសាបសូន្យឈឹង ។
៚ មិនបានចំអិនក្លិនអសោច
ប៉ុន្តែយ៉ាងហោចគ្រាន់ទីពឹង
បរិភោគបានរស់មានលំនឹង
ដើរឆ្លងវាលស្ទឹងឲ្យដល់ត្រើយ ។
៚ លុះដល់ទីដៅលាក់រឿងពិត
សល់សាច់កប់ជិតរួចស្រេចហើយ
មិនអួតប្រាប់ញាតិមិត្តណាឡើយ
ថាបានបរិភោគសាច់កូនឯង ។
៚ រឿងនេះប្រៀបដូចពុទ្ធបរិស័ទ
បានលាភហើយស្ងាត់មិនសំដែង

មិនអួតមិនមើលងាយគ្នាឯង

ប្រឹងប្រែងតំរង់ផ្លូវជីវិត ។

៦ អនុគ្រោះដល់ព្រហ្មចរិយធម៌

ថ្លាស្អាតបវរល្អពេកពិត

ដែលគួរក្រេបផឹកហើយប្រព្រឹត្ត

ជំរះផ្លូវជិតទៅនិព្វាន ។

## ៤.ប្រយ័ត្នត្រូវអានន្តរិយកម្មដោយមិនដឹងខ្លួន

៙

៚ កាលកូននៅតូចពុកម៉ែថែទាំ
ចិញ្ចឹមថ្នាក់ថ្នមឱបថើបបំពេរ
យកផ្ញើរមេដោះមិនអស់ចិត្តទេ
នឹកភ័យក្រែងគេមើលកូនមិនល្អ ។

៚ កូនឈឺម្តងៗពុកម៉ែភ័យព្រួយ
ប្តូរគ្នាបីស្ទួយដោយចិត្តស្មោះស
ថ្នាំថ្លៃប៉ុណ្ណាមិនត្អូញខ្លាចក្រ
លួងចិត្តអង្វរឲ្យកូនឆាប់ជា ។

៚ ពុកម៉ែយកទ្រូងពាំងគ្រាប់ជួសកូន
សុខចិត្តបាបខ្លួនទទួលកម្មពៀរ
ពេលកូនមានទុក្ខម៉ែពុកធានា
រ៉ាប់រងធ្វើជាខ្ញុំកូនដាច់ថ្លៃ ។

៙ មិនតែប៉ុណ្ណោះថែមមូត្រលាមក
គំរើក្អួតឈ្លក់ម៉ែកាន់ពេញដៃ
មិននឹកខ្ពើមឆ្អើមស្រឡាញ់បុត្រថ្លៃ
ថ្នមកូនយប់ថ្ងៃរវិស័យកែវភ្នែក ។

៙ ចំណែកឪខ្លះបីតបៀមលេបខ្ទុះ
អាសូរកូនប្រុសឈឺចាប់អនេក
ឪនឹកខ្លោចចិត្តអាណិតកូនពេក
កើតរោគចម្លែកឃំស្រែកឥតល្ហែ ។

៙ លុះម៉ែពុកឈឺកូនថារវល់
មានប្រាក់អាងជួលអ្នកផ្សេងឲ្យថែ
យកលេសធ្វើការរកលុយមើលម៉ែ
បាត់មុខរាប់ខែឃ្លូរៗឃើញម្តង ។

៙ ពុកម៉ែឈឺខ្លាំងពេទ្យគិតចង់ជួយ
កូនថាកុំព្រួយអាណិតគាត់ផង

ទុកគាត់រស់យូររឹតឈឺកន្លង

ឲ្យម៉ែពុកឆ្លងផុតការចុកចាប់ ។

៦ ប្រៀបមកខ្លួនយើងទោះឈឺយ៉ាងណា

ខ្វាក់ខ្វិនពិការគង់មិនចង់ស្លាប់

ផ្លូវបុណ្យមិនដើរទៅដើរផ្លូវបាប

កងចក្ររាប់ហាបឃើញជាភួងផ្កា ។

# ៥.សូមកុំភ្លេចធាតុដើម

៙ ៙ ៙

៙ សក់ រោម ក្រចក ធ្មេញ និងស្បែក
ជាធាតុលោកចែកថាមិនដឹង
ទាំងសាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង
ដល់ពេលនឹកខឹងៗអ្នកណា ? ។
៙ បេះដូង ទាច ថ្លើម វាវ ក្រពះ
សុទ្ធតែប្រែផ្លាស់អនត្តា
សួត ពោះវៀនធំ គួរអនិច្ចា
ពោះវៀនតូចផងណាអាហារថ្មី ។
៙ អាហារចាស់និងខួរក្នុងក្បាល
វិនាសគ្រប់កាលជាប្រក្រតី
ប្រមាត់ទឹកស្លេស្ម៍ ខ្ទុះឈាមក្ដី
កើតពីបច្ច័យហេតុទាំងអស់ ។
៙ សម្បោរ ខ្លាញ់ខាប់ ញើស ទឹកភ្នែក
ប្រសិនបើឆែកគ្រប់កៀនកោះ

ខ្លាញ់រាវ ទឹកមាត់ បដិកូលស្មោះ

គ្មានមនុស្សសត្វសោះនៅពីក្នុង ។

៦ ទឹករំអិលទឹកមូត្រក៏ជាធាតុ

ផ្គុំបិទចងសៀតដើមដល់ចុង

កើតជារូបមនុស្សមួយទាំងស្រុង

តែកុំជឿស្លុងភ្លេចធាតុដើម ។

# ៦.ភ្នែកពីរគង់ខុសគ្នា

៙

✍ នៅពេលវាស់ភ្នែកកាត់វ៉ែនតា

គ្រូពេទ្យប្រាប់ថាខាងស្តាំអន់

ចំណែកខាងឆ្វេងនៅល្អគ្រាន់

សតិដឹងទាន់ថាធម្មជាតិ ។

✍ ភ្នែកពីរកើតក្នុងមនុស្សតែម្នាក់

គង់ឃើញយ៉ាងជាក់ថាខុសឃ្លាត

ទំរាំតែចិត្តអ្នកផ្សេងទៀត

ធ្វើម្ដេចឲ្យជាតិដូចចិត្តយើង ។

✍📖✍

# ៧.អ្នកយាមទ្វារចិត្ត

៙ មេគោអត់ស្បែកតែងទទួល
អារម្មណ៍មិនស្រួលគ្រប់មណ្ឌដ្ឋាន
ដោយសត្វផ្សេងៗព្រួតខាំប្រាណ
បៀតបៀនរំខានឥតឧបមា ។
៙ មេគោអត់ស្បែកគឺជាចិត្ត
តោងទាមជាប់ស្អិតដោយតណ្ហា
បើគ្មានសតិប្បដ្ឋានវិបស្សនា
នៅតែឈឺផ្សាគ្រប់ៗជាតិ ។
៙ សត្វផ្សេងចោមខាំគឺកិលេស
ឲ្យតែប្រហែសបាបជ្រែកជ្រៀត
ឈ្លានពានតោង ក មិនព្រមឃ្លាត
ខាំហើយបឺតទៀតលុះស្លាប់ចិត្ត ។

✍ មហាក្សត្រតែងមានរាជអង្គរក្ស
លោកធំគ្រប់ថ្នាក់គង់មានមិត្ត
នៅចាំការពារថែបាំងបិទ
អ្នកឃាមទ្វារចិត្តគឺសតិប្បដ្ឋាន ។

✍📖✍

# ៨.ចិត្តនិងចេតសិកជាសម្បយុត្តធម៌

៙៚៙

✍ កាលចិត្តផ្សេងគ្នាកើតព្រោងព្រាត
គ្រប់មុខដោយជាតិជាកុសល
ជាកិរិយាជាអកុសល
ជាវិបាកផ្តល់ផលចំរុះ ។
✍ ចេតសិកកើតរួមនិងចិត្តណា
មានជាតិស្មើគ្នានឹងចិត្តនោះ
វេទនាក៏ស្របតាមឥតខ្ចោះ
ត្រូវគ្នាគ្មានខុសចិត្តចេតសិក ។

# ៩.របស់អនត្តា

❧ រីចក្ខុ ជាវត្ថុ មិនទៀងទាត់
កើតហើយព្រាត់ ប្រែប្រួលផ្លាស់ ចាស់ជាថ្មី
ទាំងអតីត និងអនាគត លឿនពេកក្រៃ
ចាំបាច់ថ្វី ពោលចំពោះ ភ្នែកបច្ចុប្បន្ន ។
❧ ទាំងត្រចៀក ទាំងច្រមុះ អណ្តាតកាយ
គួរនឿយណាយ កុំអាល័យ ស្តាយថ្ងៃមុន
កុំសង្ឃឹម ពេលខាងមុខ នាំទុក្ខធ្ងន់
ព្រះមានគុណ ទ្រង់សំដែង ប្រោសសាវ័ក ។
❧ បើព្យាយាម ក្រើនសតិប្បដ្ឋាន វិបស្សនា
ទើបបញ្ញា ឃើញផស្សា យតនៈ
រលត់កើត តកំណើត លឿនឥតអាក់
ហើយជឿជាក់ ថាវត្ថុៈ នេះមិនទៀង ។
❧ រួចប្រតិបត្ត ដើម្បីណាយ ឆ្ងាយពីភព
មិនងប់ជ្រប់ នឹងធម្មជាតិ ដែលតែងល្អៀង

ជូនបានសុខ ជូនមានទុក្ខ រដូចភ្លៀង
ធម៌មិនទៀង គួរចៀសវាង ទើបស្ងប់ចិត្ត ។

## ១០.មិនគួរយកធម៌ធ្វើជាខ្លួន

បញ្ចវិញ្ញាណ រមែងកើតមាន ព្រោះតែបសាទ
ប៉ះខ្ទប់នឹងរូប ទាំង៥ជាបាទ រួមផ្សំធម្មធាតុ
ហៅអាយតនៈ ។
រូបមិនឋិតថេរ បសាទប្រួលប្រែ វិញ្ញាណសង្ខតៈ
ផ្លាស់ប្ដូរមិនទៀង រៀងរាល់ខណៈ មិនគួរស្មោះស្ម័គ្រ
យកធម៌ធ្វើខ្លួន ។

# ១១.របស់ក្ដៅ

៚ ❀ ៛

⁂ អ្វីហ្ន៎ក្ដៅខ្លាំងក្នុងលោកនេះ

មិនមានភ្លើងឆេះតែក្ដៅងំ

ដុតចិត្តសត្វលោកឲ្យទួញយំ

រីករាយបន្ទំត្រឹមខាងក្រៅ ។

⁂ គឺភ្នែកច្រមុះអណ្ដាតកាយ

ត្រចៀកទាំងឡាយសុទ្ធសឹងក្ដៅ

បើជាប់ជំពាក់ច្រើនៗទៅ

មុខជាចូលផ្លូវអបាយភូមិ ។

# ១២.កុំស្តាយភ្លើងធាតុ

៙ រឿងស្លាប់សត្វលោកតែងតក់ស្លុត
តែគេចមិនផុតព្រោះកំណើត
បើចង់ចៀសស្លាប់ត្រូវចៀសកើត
ចង់ឃាត់កំណើតតមតណ្ហា ។
៙ រឿងស្លាប់មិនគួរភ័យខ្លាចសោះ
ការពិតព្រោះអស់ភ្លើងឧស្មា
វិញ្ញាណរលត់ព្រមពេលគ្នា
អាយុសង្ខារក៏បែកធ្លាយ ។
៙ គ្រាន់តែភ្លើងធាតុរលត់ទៅ
ចិត្តព្រួយសោកសៅអាល័យស្តាយ
ភ្លើងធាតុនៅឆេះអរសប្បាយ
ភ្លើងធាតុខ្វាត់ខ្វាយក៏ភ័យស្លន់ ។
៙ ការស្លាប់មិនមែនអកុសល
បើព្រួយខ្វាយខ្វល់សតិភ័ន្ត

នៅពេលមរណាសន្ធជវន

ទុគតិតាមទាន់ប្រាកដច្បាស់ ។

❧ បើថាអាក្រក់ពេលស្លាប់ទៅ

ចុះពេលរស់នៅល្អម្ដេចខ្លះ

ធម្មតាការកើតតែងព្រាត់ប្រាស

ដោយការឈឺចាស់ស្លាប់ជានិច្ច ។

## ១៣.កុំសេពគប់នឹងទោសៈ

❧ ការឃើញកំហុសអ្នកដទៃ

មិនគួរឲ្យភ័យស្មើកិលេស

ដែលត្រាំក្នុងចិត្តយើងឯណោះ

ត្រូវឈ្លួលឆាបឆេះដោយទោសៈ ។

❧ ជាអ្នកអុចអាលបង្កាត់ភ្លើង

ដុតទាំងចិត្តយើងខ្មៅប្រទ្បាក់

បើព្យាយាមធ្វើគថ្លង់ខ្វាក់

ទើបផុតគ្រោះថ្នាក់ ខុស ខូច ខាត ។

✍ សេពគប់ទោសៈធម៌លាមក

នាំធ្លាក់នរកព្រោះប្រមាទ

អត់ធ្មត់តាមព្រះពុទ្ធោវាទ

ចិត្តនឹងល្អស្អាតដូចផែនដី ។

✍ គួរខ្លាចគួរខ្ពើមចិត្តទោសៈ

ចិត្តនាំបែកបាក់ចាកខន្តី

ចាំទេជីវិតរស់សព្វថ្ងៃ

ក្រោមហេតុបច្ច័យអ្នកចាត់ចែង ។

✍📖✍

# ១៤.កំណាព្យខ្លីៗ

៙ បើមើលឃើញទោសអ្នកដទៃ
គួរតែរំពៃទោសខ្លួនផង
ធម្មតាយើងគេតែងខុសឆ្គង
ទោសធំកន្លងទោសវដ្តៈ ។
៙ ព្រោះតែអវិជ្ជានិងតណ្ហា
ឧបាទានកម្មាធម៌អប្បលក្ខណ៍
ទើបយើងកើតស្លាប់វិលឥតអាក់
ក្នុងសង្សារចក្រគ្មានឈប់ឈរ ។

# ១៥.ជឿជាក់កម្មផល ទើបឈប់ទោមនស្ស

៙ តាមព្រះពុទ្ធដីកា   កម្មណាៗជាអំពើ
មនុស្សសត្វគ្រប់គ្នាធ្វើ   តែងធ្លាក់លើខ្លួនឯងវិញ ។
៙បើយល់ដូចនេះហើយ   អាចបន្ថយទុក្ខទោម្នេញ
លាងបាបទោសៈចេញ   លែងចោទគេធ្វើទុក្ខខ្លួន ។

# ១៦.សុខទុក្ខជាផលរបស់កម្ម

✍ មិនមានអ្នកណាធ្វើ «សុខទុក្ខ»
លំបាកស្រណុកចែកគ្នាទេ
វិបាកកើតពីកម្មបុព្វេ
ដែលម្ចាស់យើងគេបានធ្វើហើយ ។

✍ បើគេធ្វើ«ទុក្ខ»ឲ្យយើងបាន
គង់ធ្វើ«សុខ»បានពុំខានឡើយ
បើធ្វើសុខឲ្យគេកើតហើយ
ម្តេចមិនធ្វើឲ្យខ្លួនឯងផង ។

✍ ឲ្យបានរួចផុតពីជរា
ព្យាធិមរណាដូចបំណង
អាសវក្កិលេសទាំងឡាយផង
ទើបឈ្មោះថាគេ«ឲ្យទុក្ខខ្លួន» ។

# ១៧.ធម៌គួរយល់ដឹង

ঌ ក្តៅនអ្វីមិនស្មើក្តៅនកិលេស
ចេះអ្វីមិនស្មើប្រតិបត្តិធម៌
លំបាកអ្វីមិនដូចនៅក្នុងគ៌ភ
គុណអ្វីមិនស្មើព្រះសាស្តា ។
ঌ ទុក្ខអ្វីមិនស្មើបញ្ចក្ខន្ធ
ធន់អ្វីមិនស្មើចិត្តមាតា
ត្រជាក់អ្វីមិនដូចធម៌មេត្តា
ខុសអ្វីមិនស្មើមានទោសៈ ។
ঌ សុខអ្វីមិនស្មើនឹងក្តីស្ងប់
ជាប់អ្វីមិនស្អិតដូចលោភៈ
ល្ងង់អ្វីក៏មិនស្មើមោហៈ
ប្រចក្សអ្វីមិនដូចសេចក្តីពិត ។
ঌ ស្រាលអ្វីមិនស្មើជម្រុះខន្ធ
ប្រកាន់អ្វីមិនស្មើនឹងជីវិត
យល់អ្វីមិនស្មើលោកមានពិត
ជារបស់វិថីចិត្តតែប៉ុណ្ណោះ ។

# ១៨.ថម្គៈក៏ជាអកុសល

៙

៚ក្នុងអដ្ឋកថា ព្រះអភិធម្មថា ចិត្តដែលរឹងត្អឹង
ប្រៀបដូចសំពត់ សាដកដែលរឹង ដោយសារទីពឹង
នឹងជាតិបាយម៉ាន ។

៚បុគ្គលជាអ្នក សំបូរថម្គៈ រមែងមិនមាន
សភាពរាបទាប លំទោនឱនប្រាណ មានះរុញច្រាន
ព្រហើនចើងមើង ។

៚កាលឃើញចេតិយ ជនចាស់ជាងក្តី វាយឫកកោងឆ្មើង
មិនបានវន្ទា គោរពគំកើង ដូចថ្លោកស្បែកឡើង
ប៉ោងពេញដោយខ្យល់ ។

៚ម៉្យាងទៀតលោកបាន ប្រៀបនឹងពស់ថ្លាន់ លេបផ្ទៀងនង្គ័ល
ឆ្អែតតឹងធំពោះ រស់ឥតបានផល មានតែអកុសល
គឺធម៌ថម្គៈ ។

(ព្រះត្រៃបិដកលេខ២០ ទំព័រ១១៧)

# ១៩.គ្រូពេទ្យក្អកមាន់

៙ កុំបានតែថាអ្នកចាតែថេះ
ខ្លួនក្អកខេះៗប្រឹងពន្យល់គេ
ឲ្យខំលេបថ្នាំខ្លួនមិនបាច់ទេ
តើអ្នកណាគេជឿពេទ្យក្អកមាន់? ។

# ២០.សុខដោយនេក្ខមៈទើបគ្រប់

៙ នៅពេលណាដែលចិត្ត
សុខស្ងប់ពិតដោយនេក្ខមៈ
ទើបលែងត្រូវពឹងពាក់
លាភយសសក្តិមាសប្រាក់ទៀត ។

# ២១.ត្រូវពិនិត្យឲ្យច្បាស់មុនសេពគប់ !

ៜ៚ៜ

✍ មិត្តខ្លះជុំគ្នាក្លែងជាសសើរ
ថាអ្នកនោះធ្វើបានល្អច្រើនផ្លូវ
ដល់ទីកំបាំងបែរជាក្រញូវ
ព្រោះចិត្តឈ្លួលក្តៅដោយធម៌ឥស្សា ។
✍ រៀបរាប់ឯបអបបំផ្លើសពន្លាត់
ចិត្តជាទេវទត្តមាត់ជាទេវតា
ពិនិត្យឲ្យច្បាស់មុនយកជាគ្នា
កុំមើលឃើញខ្លាស្មានថាកូនចៀម ។

# ២២.កុំទុកចិត្តសញ្ញា

✍ សញ្ញាចាំថាមានមាសប្រាក់
មានទ្រព្យលុយកាក់ច្រើនតិចក្តី
តាមពិតគ្មានសោះនូវអ្វីៗ
មិនខុសពីថ្ងៃបណ្តើរកូន ។

# ២៣.ជួយតែខ្លួនឯងសិនចុះ!

៙ នៅពេលកំពុងបើករថយន្ត
គួរខំគយគន់គិតមើលផ្លូវ
ប្រយ័ត្នខ្លួនឯងល្អជាងទៅ
ជួយមើលខុសត្រូវអ្នកដទៃ ។
៙ រវល់ចោលភ្នែកជួយបរគេ
តិចទម្លានយើងរជួបគ្រោះភ័យ
ធ្លាក់ក្នុងស្នាមភ្លោះទោះមិនក្ស័យ
គង់បាក់ជើងដៃខ្ចីទាំងឆ្អឹង ។
៙ ប្រៀបចិត្តបរិសុទ្ធនិងសៅហ្មង
របស់អ្នកផងគេតែងដឹង
ខ្លួនគេមិនបាច់យើងខំប្រឹង
ជួយព្រួយអរខឹងជំនួសឡើយ ។

# ២៤.ពាក្យពេយពាយនាំធ្លាក់នរក

꧁❀꧂

❧ បើចង់នាំពាក្យត្រូវចេះគិត
ហោចណាស់ពោលពិតមានខ្លឹមសារ
កុំមួលបំផ្លើសឥតបានការ
តិរច្ឆានកថាធ្លាក់អបាយ ។

❧📖❧

# ២៥.កុំកើតទុក្ខនឹងកិលេសគេ

꧁❀꧂

❧ ពេលឮពាក្យចោទខុសការពិត
ត្រូវប្រយ័ត្នចិត្តកុំខឹងត
ព្រះពុទ្ធដីកាថាមនុស្សល្អ
មិនគួរបន្តភ្លើងពីគេ ។
❧ អ្នកណាថាខុសអ្នកនោះបាប
កម្មកត់ដរាបមិនភ្លេចទេ
កុំកើតទុក្ខនឹងកិលេសគេ
ពិនិត្យមើលថៃតែចិត្តខ្លួន ។

# ២៦.លាងចិត្តយើងមុន

៙

✍ ពេលឃើញទ្បានទឹកមកដល់ហើយ

ប្រាប់ថាអ្នកអើយកុំបារម្ភ

ជួយលត់ផ្ទះគេមុនផ្ទះខ្ញុំ

គេមានទុក្ខធំខ្ញុំមិនអី ។

✍ យ៉ាងណាពេលចិត្តកើតសៅហ្មង

ប្រៀបដូចមានខ្ទងប្រទ្បាក់ដី

មិនខំដុសលាងបែរជាភ័យ

ជួសអ្នកដទៃឯណោះវិញ ។

✍📖✍

# ២៧.កុំផ្កាប់ផ្កូនលោភៈ

៙ ផ្កាប់ផ្គុនគុណធម៌ស្ងប់ត្រជាក់
ផ្កាប់ផ្គុនលោភៈទុក្ខច្រើនយ៉ាង
ផ្កាប់កាមញៀនញ៉ាមមិនងាយស្វាង
មានតែហាត់ខ្លាំងខកគំនិត ។
៙ ផ្កាប់ផ្គុនកាមគុណពិតជាស្ដាយ
ខាតពេលថៃកាយអប់រំចិត្ត
លោកាមិសៈប្លមធ្វើមិត្ត
អូសទាញយោងយឹតទៅឋានក្រោម ។

# ២៨.លោកនេះជាទ្រុងមច្ចុរាជ

៙ អភិធម្មនាំឲ្យដឹងការពិត

យល់ពីជីវិតប្រចាំថ្ងៃ

ជឿជាក់ក្នុងផលឥតសង្ស័យ

កើតពីបច្ច័យហេតុទាំងអស់ ។

៙ ស្គាល់លោកប្រាំមួយដូចស្គាល់កូន

កើតហើយប្រែសូន្យរលត់ស្មោះ

គ្រប់អាយតនៈមិនចន្លោះ

គ្មានអ្វីទៀងសោះត្រូវប្រឹងលះ ។

៙ ចិត្តចេតសិករូបមានដូចគ្នា

តែនៅចងពៀរព្រោះមានៈ

ប្រកាន់ហួងហែងបែងយកឈ្នះ

ក្នុងទ្រុងតេជះមច្ចុរាជ ។

# ២៩.អកុសលកម្មទៅដែលត្រូវវៀរ

៙ រឿងចិត្តអាក្រក់អ្នកដទៃ

មិននាំឲ្យភ័យធ្លាក់អបាយ

ចិត្តបាបក្នុងខ្លួនទើបអន្តរាយ

ត្រូវឆាប់ដោះស្រាយដុសលាងចេញ ។

៙ ពេលមានវិបាកអកុសល

គួរទទួលស្គាល់ថាចំណេញ

អរបានថយបាបលែងនៅពេញ

អកុសលកម្មវិញទើបត្រូវវៀរ ។

# ៣០.សូមកុំបានធ្លាប់ដូចគេ

✍ ធ្លាប់ពោលបំផ្លើសស្មានតែអត់ខុស
ពិតជាបាបគ្រោះមួយយ៉ាងដំណំ
ស្តាប់ឮត្រឹមល្ពៅថាប៉ុនសាលាឃុំ
ប្រាថ្នាសូមកុំបានធ្លាប់ដូចគេ ។

# ៣១.ប្រយ័ត្នកម្មកត់

✍ វីអ្នកគាំទ្របន្ទរហៃអើ
ស្របគ្រប់អំពើជួយសមគំនិត
ប្រយ័ត្នកម្មកត់ថាបានឃុបឃិត
ភ្នែកបើកធ្វើបិទតិចល្ងិតមែនទែន ។

## ៣២.ចាញ់គេចុះឲ្យតែឈ្នះខ្លួនឯង !

✍ ព្រមចាញ់ដោយចិត្តសុខស្ងប់ខន្តី
ចាញ់អ្នកដទៃតែឈ្នះខ្លួនឯង
ឈ្នះនេះព្រះពុទ្ធទ្រង់ត្រាស់សំដែង
ថាល្អក្រៃលែងឈ្នះចាស់ឈឺស្លាប់ ។

## ៣៣.ភ្នែកកើតព្រោះបុណ្យ គួរទុកធ្វើតែកម្មល្អ

✍ បើមានចក្ខុគ្រាន់ប្រព្រឹត្ត
ទ្វារបីទុច្ចរិតមិនប្រសើរ
ស៊ូខ្វាក់វិញចុះគង់គ្រាន់បើ
ព្រោះមិនបានធ្វើកម្មវេរា ។
✍ បុណ្យតែងផ្តល់ឲ្យបានភ្នែកមនុស្ស
មុខមាត់ច្រមុះសមល្អជា
តែបើធ្លាប់ធ្វើបាបកម្មពៀរ
នឹងបានភ្នែកលាសេះប្រាកដ ។

# ៣៤.ចិត្តអើយចិត្ត

៙ ចិត្តអើយចិត្តឯងកាលកើតមក
គ្មានដៃលនាំយកអ្វីមកសោះ
ម្ដេចចេះហួងហែងស្ដាយស្រណោះ
ឃើញគ្រប់របស់សុទ្ធតែល្អ ។
៙ ដល់ពេលចិត្តឯងរលត់ទៅ
គ្មានអ្វីសល់នៅក្រៅពីធម៌
ពេលចិត្តរលត់អ្វីៗក៏
រលាយបន្តព្រមពេលគ្នា ។
៙ ស្រឡាញ់ដីទឹកនឹកភ្លើងខ្យល់
នាំតែកង្វល់កើតវេរា
ប្រយ័ត្នធ្លាក់ក្នុងអន្ទាក់មារ
យកល្អការពារមុនព្យាបាល ។
៙ ត្រូវមានសតិរលឹកដឹង
ថាអាណិតខឹងត្រេកត្រអាល

ត្រឹមតែជាចិត្តកើតគ្រប់កាល
ផ្លាស់ប្តូរធូន់ស្រាលរាល់ខណៈ ។
៚ គួរគិតថានុ៎ះមិនមែនយើង
ទឹកដីខ្យល់ភ្លើងតែងជាធ្នាក់
លួងលោមអូសទាញចិត្តធ្លាក់
ជាប់ក្នុងវដ្តៈទុក្ខគ្រាំគ្រា ។
៚ ការមិនប្រកាន់ខន្ធបញ្ចកៈ
ទើបផុតមរណៈជាតិជរា
ការទៅនិព្វានក៏ដូចគ្នា
បានសេចក្តីថាលែងវិលវិញ ។
៚ បើមានបញ្ញាខំធ្វើបុណ្យ
សន្សំដើមទុនទើបចំណេញ
ភាវនាសីលប្រាំជាប់ពេញលេញ
ព្រមទាំងបំពេញទានសុចរិត ។
៚ ខន្តីសីលធម៌ល្អអស្ចារ្យ
ជាអលង្ការរបស់ចិត្ត

ឈ្នះអស់សត្រូវទោះឆ្ងាយជិត

ចោមរោមមូលមិត្តស្ម័គ្រមេត្រី ។

✍ រីការបំរើអង្គព្រះពុទ្ធ

ព្រះធម៌ល្អផុតភពផែនដី

ទាំងការបំរើព្រះសង្ឃថ្លៃ

គ្មានអ្វីប្រសើរជាងទៀតទេ ។

✍ ព្យាយាមស្តាប់ធម៌និងបដិបត្តិ

តាមព្រះបញ្ញត្តិមិនវៀចវេរ

ខំស្រូតកុំចាំពេលទំនេរ

អវិជ្ជានាំទុក្ខឲ្យខ្លួនឯង ។

✍ ភ្លៀងមាសភ្លៀងប្រាក់ធ្លាក់លើដី

មិនស្មើព្រះអរិយលោកសម្តែង

ស្តាប់ភ្លៀងព្រះធម៌ល្អចាំងចែង

សាបព្រោះតាក់តែងពូជសទ្ធា ។

✍📖✍

## ៣៥.សំដី

៙ ពាក្យមានប្រយោជន៍សិមនិយាយ
កុំអាងហាស្ដីនាំឲ្យសាប
សំដីជាផ្កាក្លិនកូឡាប
ទោះគ្រហែមស្វាបក៏គេស្ដាប់ ។

## ៣៦.សតិជាថ្នាំ

៙ សតិជាថ្នាំព្យាបាលចិត្ត
ពូកែសក្ដិសិទ្ធខាងបើកបរ
ជនខ្វះស្មារតីខ្វះធម៌ល្អ
ដូចដំរីអត់ហ្មផ្គរអត់ភ្លៀង ។
៙ សីលជាទីពឹងធំក្នុងលោក
រូបកាយមានរោគតែងរំលោង
កាលខន្ធបែកធ្លាយចោលរូបរាង
តួសីលនៅទៀងមិនស្លាប់សោះ ។

✍ សីលជួយរៀបចំរូបឲ្យល្អ

សម្លេងនោះក៏បានពីរោះ

បានកើតក្នុងវង្សត្រកូលខ្ពស់

មានសក្តិមានយសឈ្មោះល្បីក្រៃ ។

✍📖✍

# ៣៧.ស្រះទឹក

✍ អ្នកដើរហាលក្រោមកំដៅថ្ងៃ

ពងជើងពងដៃផ្សាក្រហាយ

ណាមួយស្រេកទឹកណាឃ្លានបាយ

ណាផ្លូវក៏ឆ្ងាយមិនផុតសោះ ។

✍ ស្រាប់តែបានជួបនឹងស្រះទឹក

ថ្លាធំពន្លឹកមានឈូកដុះ

ផ្លែច្រើនទុំខ្ចីល្អចំរុះ

ស្រះនោះជាឈ្មោះព្រះនិព្វាន ។

✍📖✍

# ៣៨.បំណុលកាម

៙ សេពគប់ជាមួយនឹងលោភៈ
នាំតែជំពាក់បំណុលកាម
លោភៈទាក់ចិត្តស្អិតញៀនញ៉ាម
ឲ្យក្រេវក្រវាមគ្រប់ៗជាតិ ។
៙ ដំបូងលោភក្នុងរបស់មួយ
មិនយូរកើតព្រួយចង់បានទៀត
តពីមួយជាតិទៅមួយជាតិ
កិលេសគ្រោតគ្រាតតាមជាប់កែង ។
៙ លោភៈកើតមានមួយពេលសោះ
តែឲ្យទុក្ខអស់កាលអង្វែង
កិលេសអ្នកដទៃនិងខ្លួនឯង
ពេញចិត្តក្រៃលែងព្រោះមោហ៍បាំង ។

# ៣៩.អប់រំចិត្ត

១❀៧

ஆ គប់ស្មៅដែលភ្លើងកំពុងឆេះ
តែងឆេះអ្នកកាន់ជាប់មិនលែង
ប្រៀបដូចភ្លើងកាមគួរស្លប់ស្ញែង
ឆេះងំគ្មានផ្សេងតែងដុតសត្វ ។
ஆ ព្យាយាមឃើញទោសរបស់វា
ទើបអាចរាំងរានូវវិបត្តិ
ភ្លើងកាមផ្ដល់ទុក្ខជាសម្ងាត់
អ្នកជួយកំចាត់គឺព្រះធម៌ ។
ஆ ការអប់រំចិត្តសំខាន់ក្រៃ
មានការព្រួយភ័យឬត្រេកអរ
ស្រឡាញ់ឬស្អប់ស្ញៀមញាប់ញ័រ
ថ្លាល្អក់កករព្រោះមានចិត្ត ។
ஆ នៅក្នុងពេលណាក៏ចិត្តមាន
អាចអប់រំបានមិនភ័យភិត

មិនព្រួយដើរខ្ចីឬសុំចិត្ត
អ្នកផ្សេងមកគិតកែលំអ ។
៚ ពេលឃើញរូបជាធាតុមិនដឹង
ចែកដាច់ចេញភឹងពីនាមធម៌
អ្នកមានបញ្ញាមិនញាប់ញ័រ
នៅពេលលោកធម៌ប៉ះពាល់ត្រូវ ។
៚ អ្នកឆ្លាតទុកខ្លួនដូចសាកសព
រឿងស្រទ្បាញ់ស្អប់គាប់អាស្រូវ
គឺចិត្តប៉ុណ្ណោះដឹងខុសត្រូវ
នេះឯងជាផ្លូវទៅនិព្វាន ។

# ៤០.ដំណើរធម្មយាត្រាទៅស្រីលង្កា

៙ ស្រុកស្រីលង្កាសម្បូរបុណ្យ
ទឹកដីអរហន្តលោកគង់នៅ
ព្រះពុទ្ធក៏ទ្រង់ធ្លាប់យាងទៅ
ភ្នំខ្ពស់ជ្រោះជ្រៅត្រជាក់ចិត្ត ។
៙ តែទីដែលគួរឲ្យជ្រះថ្លា
គឺព្រះសាស្ដាស្ដេចអាណិត
បន្សល់ព្រះធាតុថ្លៃពិតៗ
ឲ្យពុទ្ធបរិស័ទទាំងប្រុសស្រី ។
៙ បានថ្វាយបង្គំធាតុពីរនាទី
ក្នុងសុវណ្ណមាលិកចេតិយ
បង្កើនសទ្ធាទាំងយប់ថ្ងៃ
ដោយឧបនិស្ស័យផ្សំពីមុន ។
៙ កាលឃើញព្រះស្រីពោធិព្រឹក្ស
ដាស់ចិត្តឲ្យនឹកព្រះមានបុណ្យ

ទ្រង់មានករុណាបញ្ញាគុណ

វិសុទ្ធិគុណប្រៀបពុំបាន ។

៚ ពេលថ្វាយបង្គំព្រះនលាដ

ឧណ្ហីសធាតុដ៏ថ្កើងថ្កាន

ហាក់ដូចអណ្តែតផុតពីស្ថាន

ព្រោះមិននឹកស្មានបានមកដល់ ។

៚ ទាំងអក្ខកធាតុថ្លៃបវរ

ព្រះកេសធាតុក៏ក្របានយល់

អ្នកជួបពិតជាបុណ្យឲ្យផល

ដែលមហាកុសលកើតព្រោះហេតុ ។

៚ ពុទ្ធស្ថានពិសេសមានមួយទៀត

គឺព្រះទន្តធាតុល្អត្រដែត

គង់ក្នុងកោដ្ឋមាសខ្ពស់មួយម៉ែត្រ

វន្ទាមិនឆ្អែតទេម្ចាស់ថ្លៃ ។

៚ ដំបូលប្រក់មាសល្អអស្ចារ្យ

ពិតានមានផ្កាម្លៃប្រាំបី

ធ្វើពីមាសសុទ្ធរុងរឿងក្រៃ
រចនាដោយដៃជាងប្រណីត ។
៙ ជាទីសក្ការៈបូជា
តម្កល់ទន្ដាព្រះទ្រង់ឫទ្ធិ
ចង្កូមស្ដាំក្រោមល្អពេកពិត
ភ្លឺផ្លេកវិចិត្រដូចផ្កាយព្រឹក្ស ។
៙ ទីដែលបរិស័ទចាំរហូត
ភ្នំសុមនកូដល្អពន្លឹក
ខ្ពស់មែនតែនៅចាញ់ចិត្តនឹក
រលឹកដល់ស្នាមព្រះបាទថ្លៃ ។
៙ មនុស្សម្នាជាច្រើនទាំងក្មេងចាស់
តស៊ូខ្លាំងណាស់ប្រឹងយប់ថ្ងៃ
អ្នកខ្លះវារឡើងពាក់ស្រោមដៃ
គិតថាទោះក្ស័យក៏មិនស្ដាយ ។
៙ ចំណែកជនជាតិស្រីលង្កា
ស្រែកនមស្សកាពីចម្ងាយ

ជាមួយពួកយើងយ៉ាងសប្បាយ

ថាគេមកថ្វាយបង្គំព្រះ ។

៙ បរិស័ទខ្មែរយើងពឹងឈើច្រត់

ប្រសិនបើអត់មុខជាស្វះ

មិនងាយឡើងទេព្រះគុណម្ចាស់

ព្រោះភ្នំខ្ពស់ណាស់កប់វេហាស៍ ។

៙ ពេលឡើងទៅដល់ចិត្តល្អស្អាត

វន្ទាព្រះបាទដោយជ្រះថ្លា

ក្រាបថ្វាយបង្គំជល់សិរសា

លើស្នាមបាទាព្រះពុទ្ធថ្លៃ ។

៙ យប់នោះត្រជាក់ធ្លាក់សន្សើម

រងារញ័រថ្មើមអាសូរក្រៃ

ដល់ជនគ្មានទីស្នាក់អាស្រ័យ

សម្រាកផ្ទាល់ដីឥតអ្វីបាំង ។

៙ ពួកយើងជ្រៀតណែនពេញបន្ទប់

គង់គេងលក់ស៊ប់ព្រោះងុយខ្លាំង

ណាមួយឡើងភ្នំអស់កម្លាំង
ចាំតែភ្លឺស្រាងនឹងអាលងើប ។
๛ ទៅថ្វាយបង្គំព្រះបាទា
ពេលនមស្សការចិត្តរំភើប
ត្រេកអរសប្បាយហាក់ដូចទើប
ងើបពីស្ថានក្រោមមកសួគ៌ា ។
๛ ពេលនោះអរុណចាំងរស្មី
បច្ចុសសម័យយើងនាំគ្នា
ឈរចាំគោរពសូត្រវន្ទា
បែរទៅបូព៌ាទិសថ្ងៃរះ ។
๛ ឥមកជនជាតិស្រីលង្កា
ប្រទក្សិណបូជាដៃសំពះ
គោរពលើកទូលចង្ហាន់ព្រះ
ថ្វាយចំពោះម្ចាស់ដ៏មានគុណ ។
๛ តាំងពីព្រះអង្គចូលនិព្វាន
បរិស័ទថ្វាយទានជាប់និរន្តរ៍

ស្មើពុទ្ធសករាជជាងពីរពាន់

គិតទាំងក្រោយមុនរាល់ៗថ្ងៃ ។

๛ ចុងក្រោយឱនកាយថ្វាយបង្គំ

លាទីឧត្តមបាទាថ្លៃ

រូបកាយឆ្ងាយពិតចិត្តអាល័យ

មិនដឹងមានថ្ងៃណាជួបទៀត ។

๛ ម្ចាស់អើយទោះបីឃើញតែស្នាម

ចិត្តនឹកដិតដាមមិនរវាត

សូមជួបត្រៃរតន៍គ្រប់ៗជាតិ

កុំបីឃ្លាងឃ្លាតខុសប្រាថ្នា ។

๛ ពេលចុះពីភ្នំក៏ដូចឡើង

ឈឺចុកដៃជើងសព្វកាយា

ប៉ុន្តែកម្លាំងចិត្តជ្រះថ្លា

សប្បាយអស្ចារ្យភ្លេចឈឺចាប់ ។

๛ យើងលាកូឡេនមបូចេញឆ្ងាយហើយ

រាត្រីចុងក្រោយហាក់ផ្តាំប្រាប់

ឲ្យនឹកលង្គាមហាកំណប់

នឹកយប់ចុះអ័ព្ទពេលឡើងភ្នំ ។

✍ ពីថ្ងៃនេះទៅទោះនៅឆ្ងាយ

វាចាចិត្តកាយខំបន្ទុំ

ព្យាយាមស្តាប់ធម៌ហើយអប់រំ

ធ្វើទានសីលផ្សំបូជាព្រះ ។

# ៤១.បើអត់ខឹងទើបអត់ខុស

✍ អ្នកខ្លះត្រូវគេវាយប្រហារ

បើខ្វះបញ្ញាមិនអត់ធន់

ភ្លេចគិតបាបខ្លួនធ្វើពីមុន

វិបាកស្រាលធ្ងន់នឹងតាមផ្តល់ ។

✍ បើមានសតិរលឹកដឹង

ចិត្តស្ងប់មិនខឹងគ្មានកង្វល់

ព្រោះជឿថាពិតជាអកុសល

កម្មខ្លួនឲ្យផលតាមកំហុស ។

🙞 អ្នកដែលវាយយើងសាងជម្រុក

ខំព្រោះពូជទុកគង់នឹងដុះ

អ្នកវាយឯណោះជាអ្នកខុស

តែយើងឯណោះជាអ្នកខឹង ។

## ៤២.រង្កៀសកិលេសខ្លួនឯងវិញ

🙞 កិលេសខ្លួនឯងរាប់ពុំបាន

ត្រាំក្នុងសន្ដានជាប្រក្រតី

គួរខំប្រឹងលាងជាជាងខ្វី

ចិត្តអ្នកដទៃមករក្សា ។

🙞 ការរង្កៀស នូវកិលេស អ្នកដទៃ

មិនប្រពៃ គួរចៀសវាង លាងជំរះ

ត្រឹមចិត្តខ្លួន ឲ្យមាំមួន តាមធម៌ព្រះ
ទើបប្រទះ ការស្ងប់ចិត្ត ដ៏ពិតអស់ខ្វល់ ។

✍📖✍

## ៤៣.កុំជាប់ចិត្ត...កុំចង់បានសង្ខារធម៌

៙❀៙

✍ កុំចង់បាននូវអ្វីដែលអត់
ខន្តីអំណត់កុំស្រេកឃ្លាន
កុំជាប់ចិត្តនឹងអ្វីដែលមាន
បើអត់ធន់បានពិតជាសុខ ។
✍ អ្វីៗកើតព្រោះហេតុបច្ច័យ
គង់ជាចំណីនៃក្តីទុក្ខ
កើតហើយប្រែប្រួលមិនបានសុខ
សង្ខារជាទុក្ខព្រោះមិនទៀង ។

✍📖✍

# ៤៤.គុណរបស់សទ្ធា

៚❀៛

✍ សទ្ធាជាភ្លើងសំរាប់ដុត
ចិត្តកាចបំផុតធ្លាប់រឹងរូស
ឲ្យស្លូតទន់ភ្លន់លែងប្រទូស្ត
ចេះចង់ជួយមនុស្សគ្រប់ៗប្រាណ ។
✍ សទ្ធាជាមេភ្លើងក្នុងលោក
ដុតភាពស្មោកគ្រោកទាំងប៉ុន្មាន
ដែលប្រឡាក់ជាប់ចិត្តសន្តាន
ឲ្យស្ងប់សុខសាន្តលែងញាប់ញ័រ ។
✍ សទ្ធាជាមេដឹកនាំទ័ព
កំចាត់រំងាប់អកុសលធម៌
ដែលក្រាញតោងចិត្តស្អិតជាងជ័រ
បិទកុសលធម៌ឲ្យវិនាស ។

✍📖✍

# ៤៥.កុំខ្មាសគ្រូពេទ្យ

៙ ដឹងថាមានរោគជោគក្នុងចិត្ត
ប្រាប់ពេទ្យហើយគិតខំលេបថ្នាំ
តមចំណីទាស់ផ្សះខន្ធប្រាំ
អាសវៈគ្រឿងត្រាំគង់ខ្ជាត់ខ្ជាយ ។
៙ អ្នកឈឺធ្វើជាតឹងព្យាបាល
លាក់រោគធ្ងន់ស្រាលប្រចាំកាយ
ក្នុងក្តៅខាងក្រៅហាក់សប្បាយ
ស៊ូទ្រាំវេចស្លាយគ្រប់វេលា ។
៙ អ្នកឈឺក្នុងពេទ្យ,ពេទ្យថែទាំ
ឲ្យថ្នាំត្រូវចំរោគនឹងជា
អ្នកនៅក្រៅពេទ្យលាក់រោគា
មិនសុទ្ធតែជាទាំងអស់ទេ ។

# ៤៦.ម៉ែត្រេកអរនឹងកូនសាងផ្នួស

៙

| | | |
|---|---|---|
| ៚ម៉ែខកចិត្ត | ដ្បិតកូនលា | ចាកសិក្ខា |
| មិនហ៊ានថា | ហាវាស្លាក់ | ខ្ជាក់វាស្លែង |
| បើប្រឹងឃាត់ | នាំបាបមាត់ | តែម្នាក់ឯង |
| ទើបថ្លឹងថ្លែង | ឈប់ហួងហែង | លែងចរចា ។ |
| ៚បើជាប្រុស | ម៉ែនឹងបួស | ជំនួសកូន |
| តែលាភសូន្យ | ជោគអាប់ឱន | ភេទហីនា |
| មិនអនុញ្ញាត | ឲ្យស្ត្រី | សាងបព្វជ្ជា |
| ដូចកាលគ្រា | ព្រះសាស្តា | គង់នៅឡើយ ។ |
| ៚មិនថ្វីទេ | បើពេលនេះ | ហេតុបច្ច័យ |
| អូសទាញដៃ | កូនប្រុសថ្លៃ | ឆ្ងាយពីត្រើយ |
| ទោះម៉ែតឹង | ចង្អៀតចិត្ត | ក៏ពិតហើយ |
| ប៉ុន្តែល្ហើយ | គង់ពេលក្រោយ | កូននឹងយល់ ។ |
| ៚ថាមាសប្រាក់ | លាភយសសក្តិ | ថ្នាក់មន្ត្រី |
| ទាំងសេដ្ឋី | សេនាបតី | ស្តេចទ្រង់ពល |

គង់នៅចាញ់ កម្លាំងបុណ្យ ផ្ទុសឲ្យផល
ជាកុសល នាំកូនដល់ ថ្នល់និព្វាន ។
៙កូនដឹងទេ ក្រពេកក្រៃ បច្ច័យល្មម
ក្រដល់ព្រម ទាំងសទ្ធា ដែលកូនមាន
ក្របានកើត មកជាមនុស្ស ទាំងធនធាន
ក្រធម្មយាន ព្រះប្រទាន ទុកកេរ្តិ៍ឲ្យ ។
៙ក្រម៉្យាងទៀត ក្រកើតទាន់ ពុទ្ធសាសនា
ក្រអាចារ្យ ប្រោសទេសនា គ្រប់ជ្រុងជ្រោយ
ថ្ងៃមរណៈ កាន់តែខិត ជិតណាស់ហើយ
មាសម្តាយអ្ហើយ! ម្តេចកន្តើយ លែងខន្តី? ។
៙ក្នុងលោកនេះ គ្មានអ្វីសោះ ជាទីពួន
ឲ្យកូនសួន បានរួចខ្លួន ចាកទុក្ខភ័យ
តែបើអ្នក ពឹងលើព្រះ រតនត្រ័យ
កូនប្រុសថ្លៃ រួចភពបី ផុតទារុណ ។
៙កាលកូនបួស សមឥតខ្ចោះ ម៉ែញញឹម
មានសង្ឃឹម កូនថ្វាយខ្លួន បម្រើបុណ្យ

តែទោះសឹក ក៏កុំឆ្ងាយ ពីពុទ្ធគុណ
ម៉ែភ័យស្លន់ ខ្លាចតណ្ហា ខ្ញីកូនប្រើ ។

## ៤៧.ត្រូវជួយខ្លួនដោយខ្លួនឯង

✍ បរិភោគបាយទឹក រាល់ពេលល្ងាចព្រឹក
បំបាត់ស្រេកឃ្លាន បើមិនហូបទេ
ពិតជាមិនមាន អ្នកទទួលទាន
ជំនួសយើងបាន ។

✍ យ៉ាងណាកិលេស កណ្តាញ់ចាក់ស្រេះ
នៅក្នុងសន្តាន ត្រូវខំដុសខាត់
ខ្លួនឯងកុំខាន ញាតិទាំងប៉ុន្មាន
ជួយពុំបានឡើយ ។

# ៤៨.នឹកស្រុកព្រះណាស់

៙ នឹកស្រុកព្រះណាស់ម្ចាស់ថ្លៃអើយ
នឹកមិនភ្លេចឡើយក្រោយពីបាន
ទៅថ្វាយបង្គំទីថ្កើងថ្កាន
សំវេជ្ជនីយដ្ឋានបួនកន្លែង ។
៙ ទាំងពេលបើកភ្នែកទាំងពេលធ្មេច
នឹកឃើញជានិច្ចតែម្នាក់ឯង
នឹកអស់សព្វឋានព្រះអង្គតែង
និមន្តខ្វាត់ខ្វែងគង់ប្រើប្រាស់ ។
៙ នឹកខ្លាំងជាងគេពុទ្ធគយា
ទីព្រះភគវាធ្លាប់បានត្រាស់
មហាពោធិ៍ភស្តុតាងបញ្ជាក់ច្បាស់
ឲ្យនឹកខ្លាំងណាស់រៀងរាល់ថ្ងៃ ។
៙ តមកនឹកដល់ឈាបនដ្ឋាន
និងទីនិព្វានព្រះចមថ្លៃ
ស្តេចយាងនៅពេលបច្ឆសម័យ

សុក្រពេញបូរមីណ៍ខែពិសាខ ។

๛ រួចហើយចិត្តនឹកទៅកន្លែង

ព្រះអង្គសម្តែងព្រះធម្មចក្ក

កំណើតព្រះធម៌ព្រះសង្ឃជាក់

ប្រោសអង្គសាវ័កបញ្ចវគ្គី ។

๛ ឯទីប្រសូត្រក៏អស្ចារ្យ

ឥន្ទព្រហ្មទេវតាមនុស្សមូលមីរ

ចាំថ្វាយបង្គំព្រះមុនី

ទាំងមហាប្រឹថពីក៏រញ្ជួយ ។

๛ ត្រេកអរទទួលព្រះមានបុណ្យ

ប្រោសសត្វគ្រប់ជាន់បាត់ទុក្ខព្រួយ

ក្នុងលោកមានតែព្រះអង្គមួយ

ជាទីពឹងជួយលុះអមតៈ ។

๛ រួចបានអនុមោទនានឹកដល់

មហាបុណ្យកុសលព្រះកស្សបៈ

ទូលពុទ្ធបាទថ្លៃលើសិរ្សៈ

គោរពស្មោះស្ម័គ្រឥតគណនា ។

🙞 រួចនឹកដល់គុណព្រះអរិយសង្ឃ
លោកបានចងក្រងសង្គាយនា
ព្រះធម៌វិន័យថ្លៃមហិមា
ឲ្យយើងរាល់គ្នាប្រតិបត្តិតាម ។
🙞 ខំកាត់ពីឆ្ងាយថ្វាយបង្គំ
តែស្ងាត់ជ្រងំឃើញតែស្នាម
សល់តែទីព្រៃវត្តអារាម
ចិត្តរឹតដិតដាមនឹកព្រះពុទ្ធ ។
🙞 អ្នកខ្លះទ្រាំបាននៅធម្មតា
អ្នកខ្លះសោកាយំរន្ធត់
ស្តាយមិនបានជួបព្រះសុគត
ព្រះទ័យបរិសុទ្ធស្អាតផូរផង់ ។
🙞 តែទោះមិនទាន់បានជួបក្តី
ក៏ពុទ្ធវិន័យនៅត្រចង់
បើព្យាយាមរៀនដោយផ្ចិតផ្ចង់
អរិយមគ្គនាំត្រង់ទៅជួបព្រះ ។

# ៤៩.ព្រះគុណម្ចាស់ជាបុរសផ្កាយ

៙ គួរជ្រះថ្លា នឹងសទ្ធា ព្រះគុណម្ចាស់
កំរណាស់ លះបង់កាយ ថ្វាយព្រះទ័យ
គោរពជឿ ស្ម័គ្រស្មោះលើ គុណកែវបី
ធម៌វិន័យ ក៏ម្ចាស់ថ្លៃ បដិបត្តិបាន ។

៙ លោកព្យាយាម ត្រាច់ចរតាម ពុទ្ធោវាទ
មិនព្រមឃ្លាត ស្នាមព្រះបាទ ព្រះទ្រង់ញាណ
មិនងាករេ ពីទិសដៅ ទៅនិព្វាន
លោកសមមាន ព្រះនាមជា បុរសផ្កាយ ។

៙ រីឯមនុស្ស ស្លឹកឈើជ្រុះ ខ្វះអំណត់
មិនប្រាកដ ជ្រុះទីណា ទោះជិតឆ្ងាយ
តែងញាប់ញ័រ តាមលោកធម៌ បក់ផាត់ផាយ
នាំចិត្តកាយ ឲ្យនឿយណាយ ចាកទិសដៅ ។

# ៥០.តាមហេតុបច្ច័យចុះ!

គួរហ្វឹកហាត់ ឲ្យចេះព្រម ល្មមឃោគយល់
ចេះប្រគល់ ការខុសត្រូវ ទៅឲ្យចិត្ត
ទូន្មានខ្លួន ឲ្យមាំមួន ស្គាល់ការពិត
ក្នុងជីវិត ពិតផុតទុក្ខ សុខល្ហែល្ហើយ ។
កុំចាំបាច់ ចង់កែប្រែ រឿងខាងក្រៅ
ឲ្យបានត្រូវ ទៅតាមចិត្ត នៃខ្លួនឡើយ
ហេតុបច្ច័យ ច្នៃគួរប្លង់ ផ្គង់ស្រេចហើយ
លុះដល់ត្រើយ ស្បើយក្តីទុក្ខ សុខឧត្តម ។

# ៥១.រឿងពិតរបស់ជីវិត

ជួនបាបលាមក ចោលក្លិនអាក្រក់ អសោចអស្វារ្យ
ជួនមានកុសល ក្រអូបជាងផ្កា គួរពិចារណា
បញ្ហាជីវិត ។

មនុស្សលោកទោម្នេញ កន្ទក់កន្ទេញ ក្តៅក្រហាយចិត្ត
មកពីមិនយល់ ថានេះរឿងពិត របស់ជីវិត
វាយ៉ាងហ្នឹងឯង ។
មិនតែប៉ុណ្ណោះ ថែមទាំងគិតខុស ប្រកាន់ហួងហែង
ថាជីវិតនេះ ជាតួខ្លួនឯង ទើបទុក្ខប្រទ្បែង
គ្មានពេលរលត់ ។
មនុស្សលោកល្ងង់ណាស់ ស្លាប់ទៅទាំងខ្វះ ទាំងការតក់ស្លុត
សប្បាយមិនឆ្អែត គ្មានទីបំផុត ទោះដល់ថ្ងៃដុត
ក៏នៅប្រាថ្នា ។
មនុស្សលោកល្ងង់ពិត ប្រៀបដូចសុខចិត្ត ឲ្យសាច់គេអារ
ក្លាយជារបួស ដំបៅឈឺផ្សា ទើបខំរក្សា
បិទលាងមេរោគ ។
អ្នកប្រាជ្ញនឹងន ឃើញសង្ខារធម៌ កើតមកក្នុងលោក
មិនបានរីករាយ ត្រេកអរចាប់យក ទាំងមិនសោយសោក
ពេលធម៌បាត់បង់ ។

# ៥២.ផ្លូវនៃសេចក្ដីសុខ

សុខណាស់ស្ងប់ណាស់ ពេលបានយល់ច្បាស់ ពីរឿងជីវិត
ដឹងថាក្នុងលោក មានសុខទុក្ខពិត តែមិនបានគិត
ជារឿងខ្លួនឯង។

អប់រំឲ្យដល់ ទើបចិត្តលែងខ្វល់ ប្រកាន់ហួងហែង
ប្រគល់រឿងរ៉ាវ លើហេតុចាត់ចែង បច្ច័យតាក់តែង
នឹងបានសុខស្ងប់ ។

សុខនេះប្រណីត ឧត្ដមពេកពិត ជាងទ្រព្យកំណប់
អ្វីក៏ប្រសើរ មិនស្មើសុខស្ងប់ ដល់ទីបញ្ចប់
និព្វានរង់ចាំ ។

# ៥៣.ព្រះន័យព្រះអគ្គសាវ័ក

៙ ព្រះសារីបុត្តទូលព្រះថា
ហេតុខ្ញុំព្រះករុណាមិនអាល័យ
មិនត្រេកអរនឹងវេទនាបី
សូមថ្វាយសេចក្តីដូច្នេះថា ។
៙ វេទនាទាំងបីមិនទៀងទាត់
កើតហើយប្រាសព្រាត់គ្រប់វេលា
ទោះចិត្តបានសោយសុខវេទនា
គង់ប្រែគ្រាំគ្រាជាទុក្ខព្រួយ ។
៙ ព្រះពុទ្ធទទួលថាសាធុ !!!
អ្នកមានអាយុពិតជាជួយ
ការសោយអារម្មណ៍ឯណាមួយ
ក្នុងលោកទុក្ខព្រួយនឹងមានខ្លាំង ។
៙ ការសោយវេទនាគ្រប់ប្រភេទ
យំកិញ្ចិវេទយិតំតំ (តាំងៗ)

ទុក្ខស្មិន្តិទុក្ខកើតខ្លាំង
បើនៅពឹងអាងធម៌លោកិយ ។
៚ ចិត្តព្រះអរហន្តមិនញាប់ញ័រ
ពេលជួបលោកធម៌ទាំងប្រាំបី
លោកដាក់ចិត្តកាយដូចផែនដី
ទទួលគ្រប់អ្វីៗដែលមកដល់ ។

## ៥៤.បើចង់ឲ្យគ្រប់ត្រូវឈប់ចង់!

៚ អ្នកបានរាល់ថ្ងៃរឹតតែចង់
មិនអស់ចំណង់នៅតែប៉ង
ចំណែកអ្នកបានយូរៗម្តង
មិនដូចបំណងត្រូវចេះទប់ ។
៚ ចំណង់កើតពីកាមតណ្ហា
នាំចិត្តប្រាថ្នាចង់គ្មានឈប់
តាំងពីព្រលឹមទល់ព្រលប់
បើចង់ឲ្យគ្រប់ត្រូវឈប់ចង់ ។

# ៥៥.ឈ្នះខ្លួនឯងទើបប្រសើរ

ঌ❀ও

✍ ឈ្នះអ្នកដទៃនាំមានពៀរ
ឈ្នះកិលេសមារសុខអង្វែង
ឈ្នះគេនៅតែព្រួយចំបែង
ការឈ្នះខ្លួនឯងទើបប្រសើរ ។

✍📖✍

# ៥៦.បរិជិណ្ណមិទំ រូបំ រោគនិទ្ធំ បភង្គុណំ ភិជ្ជតិ បូតិ សន្ទេហោ មរណន្តំ ហិជីវិតំ

ঌ❀ও

✍ បរិជិណ្ណមិទំរូបំ ភ្លើងធាតុដុតខ្លាំង ឲ្យរូបគ្រាំគ្រា
ចាស់ទៅរាល់ថ្ងៃ គ្មានអ្វីការពារ ចំណែកជរា
ក៏មិនយល់យោគ ។

✍ រោគនិទ្ធំ រូបកាយឈឺខ្លាំង ព្រោះចាញ់កលលោក
កាយនេះពិតជា សំបុកនៃរោគ ជីវិតស្មោកគ្រោក
ព្រោះលោកប្រាំមួយ ។

☙ បភង្គុណំ សុទ្ធតែជាខ្នាំង មិនអាចនឹងជួយ
កុំឲ្យកាយនេះ ពុកផុយរលួយ គង់ថ្ងៃណាមួយ
រូបត្រូវរលាយ ។

☙ ឯភិជ្ជតិនោះ សុទ្ធសឹងជាឈ្មោះ នៃការងាប់ងាយ
មិនយូរប៉ុន្មាន ខ្លួនប្រាណបែកធ្លាយ ប្រាសព្រាត់រាត់រាយ
គួរស្លុតអនេក ។

☙ រីពាក្យថាបូ តិសន្ទេហោ លោកប្រែបំបែក
ថាកាយខ្លួនស្អុយ អសោចក្រៃពេក គួរឲ្យសង្វេគ
នឹងធម៌អនត្តា ។

☙ រីមរណន្តំ ហិជីវិតំ ក៏ខ្លាំងអស្ចារ្យ
ព្រោះជីវិតនេះ ទោះនៅទីណា ក៏ត្រូវមានការ
ស្លាប់ជាបញ្ចប់ ។

☙ លុះត្រាតែដល់ ថ្នាក់អរហត្តផល ទើបពិតជាស្ងប់
ផុតការកើតស្លាប់ ជីវិតត្រូវចប់ លែងស្រទ្បាញ់ស្អប់
លាហើយភពបី ។

☙📖✍

# ៥៧.កុំសេពគប់នឹងសាឋេយ្យៈ

៙

ព្រះពុទ្ធត្រាស់ថាសាឋេយ្យៈ ក៏នៅក្នុងអកុសលមូល
ឯបអបអួតអាងជាចិត្តពុល ពុតត្បុតបុគ្គលបិទកំហុស ។
លាក់គុនវិជ្ជាគ្មានក្នុងខ្លួន ធ្វើហាក់មាំមួនមិនឲ្យខុស
ឃើញពួកត្រីមកក៏ត្រដុស បង្ហាញកន្ទុយថាយើងជា ។
ហ្វូងមច្ឆជាតិដូចអ្នកដែរ ឃើញពស់មកក្បែរក៏សសៀរ
បង្ហាញក្បាលថាយើងក៏ជា សត្វពស់ដូចគ្នាពិតណាអ្នក ។
ចំណែកគម្ពីរអដ្ឋកថា ព្រះអភិធម្មថាជនណាម្នាក់
ដែលប្រកបដោយសាឋេយ្យៈ មានភាពមិនជាក់ម៉ ! មែ ! អ៊ូក។
មើលពីខាងស្តាំដូចពពែ ត្រឡប់ឆ្វេងបែរដូចសត្វជ្រូក
សម្លេងដូចចៀមស្រែកប្រកូក បើមើលទៅស្នែងដូចគោចាស់ ។

(ដកស្រង់ចាកគម្ពីរព្រះត្រៃបិដក ភាគទី២០ ទំព័រ ១១៦)

# ៥៨.ចិត្តយើងចិត្តគេ

៙ បើយើងចង់រស់គេក៏ខ្លាចស្លាប់
ខ្លាចភាពឈឺចាប់ខ្លាចទណ្ឌអាជ្ញា
ទោសៈឆេះស៊ប់គប់វាយប្រហារ
គួរពិចារណាចិត្តយើងចិត្តគេ ។

# ៥៩.អត់ធន់៣ប្រការ

៙ អត់ធន់មិនខឹងនឹងអ្នកដទៃ
ជាទានអភ័យគួរឲ្យជ្រះថ្លា
សម្លាប់ទោសៈក្នុងចិត្តអាត្មា
ប្រសើរជាងការមើលឃើញគេខុស ។
៙ អត់ធន់ម្យ៉ាងទៀតនឹងចិត្តលោភៈ
ពេលជាប់ជំពាក់តែងភ្លេចសន្តោស
បើរឭកទាន់យកសតិឆ្លុះ
ទើបរួចពីទោសតាមឆទ្វារា ។

✍ អត់ធន់ទីបីលះក្តីមោហៈ

ជឿប្រាកដជាក់គ្រប់ពេលវេលា

ថារូបនេះតែងមានចាស់ជរា

ឈឺស្លាប់កម្មពៀរជាប់តាមជានិច្ច ។

# ៦០.រលកលោកធម៌

រលកលោកធម៌ បោកចិត្តឲ្យញ័រ រំភើបខ្វល់ខ្វាយ
ជួនព្រួយកើតទុក្ខ ជួនសុខសប្បាយ ជួនព្រាត់ប្រាសឆ្ងាយ
ពីសម្បជ្ជញ្ញៈ ។
ជួនមានបុណ្យខ្ពស់ បានជួបលាភយស ភ្លេចទោសមរណៈ
មុជជ្រៅក្នុងភព ជ្រប់ក្នុងវដ្តៈ ទំរាំដឹងជាក់
ហួសអស់មួយជាតិ ។
ដល់ពេលអស់បុណ្យ លាភយសពីមុន សាបសូន្យចោលម្សៀត
បើមិនថៃចិត្ត ប្រយ័ត្នមារយាទ មុខជាភ្លាត់ស្នៀត
យំសោកបោកប្រាណ ។
ពេលគេសសើរ ត្រេកអរគ្រាន់បើ ចិត្តស្រួលសុខសាន្ត

បើគេនិន្ទា ដូចជារំខាន ក្តៅទ្រាំមិនបាន
រាប់អានមិនឃូរ ។
ធម្មតាការពិត នៅក្នុងជីវិត ទោះល្វីងចត់ជូរ
ត្រូវព្រមទទួល ស្រុះស្រួលបន្ទូរ រសឆ្ងាញ់គ្មានគូ
គឺសច្ចធម៌ ។

# ៦១.ធម៌គួរពិចារណា ៨ យ៉ាង

ចំពោះបុគ្គលដែលមានបញ្ញា
គួរពិចារណាធម៌ប្រាំបីយ៉ាង
ព្រះឃោសាចារ្យតាក់តែងកសាង
ជាគ្រឿងសំអាងលាងចិត្តល្អ ។
គិតថាក្តីស្លាប់មានគ្រប់វេលា
ប្រៀបដូចគេឃារដាវភ្ជង់នឹងក
បើដល់ពេលហើយមិនអាចអង្វរ
ដាវមុតកាត់កងាយនឹងស្លាប់បាន ។

๛ ពេលសុខរីករាយបានជួបជុំញាតិ

គង់ឃំព្រោះឃ្លាតមិនយូរប៉ុន្មាន

ជួបព្រាត់កើតស្លាប់ធម៌ពីបូរាណ

អន្ទោលតាមប្រាណកុំស្មានថាទៀង ។

๛ ទោះស្ដេចគហបតីចៀសស្លាប់មិនផុត

សូម្បីព្រះពុទ្ធដល់ពេលក៏យាង

មោគ្គលានមានឫទ្ធិជាន់ទេវលោកផ្សៀង

គង់មិនអាចវាងពីការស្លាប់បាន ។

๛ រូបនេះអាចជាសាធារណកាយ

តែងស្លាប់អន្តរាយដោយការរំខាន

ពីទឹកភ្លើងខ្យល់រោគគ្រប់សណ្ឋាន

ទាំងមនុស្សតិរច្ឆានតែងបានសម្ងួស្ស ។

๛ មហាភូតរូបបួនជួនខ្សោយទុព្វល

អាចស្លាប់ដោយខ្យល់បក់ជ្រុលរង្វាស់

រត់មិនស្មើគ្នាដូចជាគេខ្វាស់

បង្កើតទំនាស់ផ្ដាច់អស់សង្ខារ ។

✍ អនិមិត្តោគ្មានគ្រឿងសំគាល់

ប្រាប់ឲ្យដឹងយល់ថាស្លាប់ពេលណា

ព្យាយាមស្ដាប់ធម៌បដិបត្តិសិក្សា

ទើបកើតបញ្ញាព្រមការម្រឹត្យូវ ។

✍ម្យ៉ាងទៀតគួរយល់ពីអាយុក្ខ័យ

ដែលជនប្រុសស្រីសម័យឥឡូវ

មានត្រឹមចិតប្រាំប្រចាំរដូវ

មិនសមរស់នៅក្នុងក្ដីប្រមាទ ។

✍ ជីវិតកើតស្លាប់រៀងរាល់ខណៈ

មិនគួរបដិបក្ខក្រៅពីសង្វាត

ព្យាយាមសិក្សាតាមព្រះឱវាទ

សន្សំចិត្តឆ្លាតសំអាតចិត្តបាប ។

✍📖✍

# ៦២.អ្វីដែលគួរខ្លាចពិតប្រាកដ

៙❀៙

✍ អ្នកខ្លះខ្លាចឈឺខ្លាចចាស់ជរា
ខ្លាចទុក្ខវេទនាខ្លាចពៀរឲ្យផល
ខ្លាចការព្រាត់ប្រាសខ្លាចស្លាប់មកដល់
ខ្លាចចោររំលបលប់ចូលលួចចូលប្លន់ ។
✍ ខ្លះខ្លាចរន្ទះខ្លាចខ្យល់ក្ួចព្យុះ
ខ្លាចភ្នំភ្លើងផ្ទុះខ្លាចរោគអាសន្ន
ខ្លាចទាំងដីប្រេះខ្លាចទឹកជំនន់
បួងសួងបន់ស្រន់សូមចៀសឲ្យឆ្ងាយ ។
✍ តាមពិតលោភៈទោសៈមោហៈ
ចោរក្នុងអប្បលក្ខណ៍នាំធ្លាក់អបាយ
គួរខ្លាចលើសខ្មាំងខាងក្រៅទាំងឡាយ
គ្មានអ្វីអន្តរាយជាងចោរនេះឡើយ ។

✍📖✍

# ៦៣.តុលាការត្បាញអោយ

✍ ចៅក្រមលំអៀងឥតពិចារណា
ជឿអ្នកឥស្សរាមុសាបំភ័ន្ត
អ្នកត្រូវឲ្យទោសខុសអោយរង្វាន់
តែកម្មតាមទាន់ផាកគ្មានយល់មុខ ។

# ៦៤.សត្វលោកដូចគ្នាដោយធម៌

✍ បើគិតតាមឋានៈ លោភយសសក្តិខុសដាច់គ្នា
នរកប្រេតព្រហ្មា មនុស្សទេវតាសត្វតិរច្ឆាន ។
✍ សឹងកើតពីបាបបុណ្យ ធ្វើពេលមុននាំឲ្យបាន
ចាប់ភពគ្រប់ទីស្ថាន ល្អសាមាន្យខ្ពស់និងទាប ។
✍ តែកាលបើទោសៈ លោភមោហៈចូលពេញប្រៀប
ចិត្តជនខ្ពស់ឬទាប ធម៌ថោកជ្រាបទាបស្មើគ្នា ។

# ៦៥.ហេតុតែរបស់ខ្ចីគេ

✍ ហេតុតែមិនមែនរបស់យើង

ខ្លួនប្រាណដៃជើងឈឺចុកចាប់

ហាមឃាត់អង្វរក៏មិនស្តាប់

ព្រោះអ្នកតែងច្បាប់គឺកម្មផល ។

# ៦៦.គួរឲ្យទានតែរបស់ល្អ

✍ ចិត្តសម្បូរអ្វីទើបចែកគេបាន

បើចង់ឲ្យទានឲ្យរបស់ល្អ

នៅពេលខឹងក្រោធកុំចែកបន្ត

ទោសៈបង្ករជាភ្លើងនរក ។

# ៦៧.កុំកាន់ជើងខ្លួនឯង !

ឥ❀ឲ

ﻬ នៅពេលខ្លួនឯងប្រព្រឹត្តខុស
តែងតែអត់ទោសធ្វើមិនដឹង
បើអ្នកដទៃខុសអញ្ចឹង
ប្រកាន់ចិត្តខឹងគ្មានមេត្តា ។

ﻬ នេះក៏ជាទោសនៃលោភចិត្ត
ស្រឡាញ់ជាប់ស្និតរូបអនត្តា
ភ្លេចគិតខន្ធប្រាំចាំប្រហារ
កើតស្លាប់ច្រើនសារឥតបានគិត ។

ﻬ ចិត្តអើយកុំយំកុំឈឺចាប់
វិញ្ញាណតែងប្រាប់រឿងមិនពិត
សុខទុក្ខមានក្នុងតែការគិត
គួរទុកជីវិតដូចចណ្ឌាល ។

# ៦៨.ការផ្សេងគ្នារវាងបុថុជ្ជននិងអរិយបុគ្គល

៙ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា
បុថុជ្ជនណាដែលកន្លង
មិនបានអប់រំកាយចិត្តផង
នឹងកើតសៅហ្មងមិនខានឡើយ ។
៙ បុគ្គលដែលមានអវិជ្ជា
លុះសុខវេទនាពាល់ត្រូវហើយ
ក៏មានតម្រេកខ្លាំងឥតស្បើយ
លង់លក់ងប់ដោយក្តីសុខនោះ ។
ពេលសុខវេទនារលត់ទៅ
ក្តីទុក្ខសោកសៅកើតចំពោះ
បុគ្គលដែលជាបុថុជ្ជននោះ
ឲ្យលំបាកហួសខ្សឹកខ្សួលយំ ។
គក់ទ្រូងដល់នូវក្តីវង្វេង
ឆេះក្តៅម្នាក់ឯងដូចភ្លើងភ្នំ

ព្រោះតែប្រមាទភ្លេចអប់រំ
ទើបទុក្ខឆេះងំសង្កត់ចិត្ត ។
ចំណែកបុគ្គលអរិយសាវ័ក
ក្នុងលោកជាអ្នកចេះដឹងពិត
ទោះបានសោយសុខហួសកំរិត
ក៏មិនលង់ចិត្តចោលគុណធម៌ ។

## ៦៩.មហាភូតរូប ៤ ដូចជាដុំពពុះទឹក

៙ កូនក្មេងខឹងឡើងអាងតែយំ
ចំណែកចាស់ទុំអាងតែស្លាប់
ជនពាលប្រមាទអាងចាក់កាប់
បណ្ឌិតអាងច្បាប់ធម៌វិន័យ ។
៙ ជនខ្លះអាងលាភយសទ្រព្យធន
ខ្លះអាងប្រពន្ធកូនស្វាមី
ភ្លេចគិតថាសុទ្ធជាចំណី
ភ្លើងខ្យល់ទឹកដីគ្រប់ៗគ្នា ។

✍ ខន្ធប្រាំដោយរោគមកពីនាយ
សតិរាយមាយឈឺថាជា
ពឹងមហាភូតរូបដែលធានា
ចាំជួយការពារក្នុងសុបិន ។

✍📖✍

## ៧០.ត្រូវផ្សំធាតុ

៙❀៙

✍ ធ្លាប់ឮថានាងរត់រកអ្នក
រីឯខាតលក្ខណ៍រកបាក់អន្សា
ជំទាវរត់រកអ្នកឧកញ៉ា
បវរធីតារកមហាក្សត្រ ។
✍ ធាតុខ្មោចនិងខ្មោចរត់រកគ្នា
រីពួកទេវាក៏ស្វែងកាត់
រកទេពធីតាតាមបុណ្យចាត់
រួមថ្លើមប្រម៉ាត់រស់សុខសាន្ត ។
✍ ធាតុធម៌រត់រកធាតុសីលទាន

អ្នកធ្វើបាបញៀនសេពគប់បាន
តែនឹងពាលមិត្តចិត្តសាមាន្យ
បៀតបៀនរំខានមនុស្សផងគ្នា ។
☙ ល្ងង់រត់រកមិច្ឆាទិដ្ឋិ
កើតរោគសតិមើលពុំជា
លើកខ្លួនជាស្តេចព្រះភគវា
ធ្លាក់នរកមួយគ្រាក្រែងជាគ្រាន់ ។

## ៧១.វិយោគកថា

☙ យើងខ្ញុំបរិស័ទទាំងអស់គ្នា
សូមក្រាបវន្ទាថ្វាយបង្គំ
ព្រះវីរសង្ឃដ៏ឧត្តម
ជាបង្គោលធំក្នុងសាសនា ។
☙ ពួកយើងតក់ស្លុតសង្វេគណាស់
ពេលព្រះលោកម្ចាស់អស់សង្ខារ
សែនស្តាយសាវ័កព្រះសាស្តា

កំពុងជ្រះថ្លាធ្វើធម្មទាន ។

ៜ លោកបានសិក្សាយ៉ាងមធ្យ័ត

ព្រមទាំងប្រតិបត្តិនិងទូន្មាន

ខ្លួនឯងដោយល្អកំរមាន

ញោមញាតិព្រៀងលានកោតគោរព ។

ៜ ម្យ៉ាងទៀតលោកម្ចាស់តែងទេសនា

តាមពុទ្ធដីកាគ្មានឈរឈប់

ពន្យល់អប់រំដោយសព្វគ្រប់

មិនថាព្រលប់ឬព្រលឹម ។

ៜ បង្កើនសទ្ធាពុទ្ធបរិស័ទ

បញ្ញាធំធាត់ដើរទន្ទឹម

ធ្វើឲ្យអ្នករៀនមានសង្ឃឹម

ត្រេកអរញញឹមព្រោះយល់ច្បាស់ ។

ៜ មិនតែប៉ុណ្ណោះលោករៀបចំ

ក្បួនខ្នាតតូចធំតាមធម៌ព្រះ

បកប្រែឲ្យងាយស្រួលយល់ណាស់

ទោះក្នុងពេលខ្លះលោកនឿយហត់ ។

ৢ លោកតែងប្រណាំងពេលវេលា

ប្រឹងធ្វើការងារយ៉ាងម៉ត់ចត់

ទោះអាពាធខ្លាំងគ្របសង្កត់

ក៏លោកអត់ធ្មត់ខំព្យាយាម ។

ৢ ក្នុងតួនាទីបុត្រព្រះពុទ្ធ

លោកទើបតែច្យុតទៅភ្លាមៗ

ម្ចាស់អើយបាត់ហើយកាយសាច់ឈាម

សល់តែព្រះនាមក្រអូបក្រៃ ។

ৢ ពួកយើងបរិស័ទសែនសោកស្តាយ

ស្មើរគ្មានរសាយទេម្ចាស់ថ្លៃ

ស្តាយអង្គសាវ័កព្រះចមត្រៃ

ដែលលោកក្សិណក្ស័យមិនបានលា ។

ৢ ក្នុងនាមព្រះសង្ឃល្អបរិសុទ្ធ

ព្រះទ័យមោះមុតឥតរួញរា

មិនជាប់ជំពាក់អ្វីនានា

មុខជាទៅស្ថានសួគ៌សុខសល់ ។

✍ ព្រះសង្ឃគ្រហស្ថទាំងអស់គ្នា

បង្គំវន្ទាឧទ្ទិសផល

លើកបុណ្យតូចធំមហាកុសល

សូមប្រគេនដល់លោកម្ចាស់ផង ។

✍ អគ្គបណ្ឌិតោយង់សុផាត

បញ្ញាឈ្លាសឆ្លាតពេកកន្លង

ជាតិនេះលោកបានដូចបំណង

រៀបក្បូនជិះឆ្លងតាមអរិយមគ្គ ។

✍ អនិច្ចាវត្តសង្ខារា

ទោះព្រះសាស្ដានិងសាវ័ក

គ្រប់អង្គទាំងព្រះឯតទគ្គៈ

ក៏គង់ច្បាស់ជាក់ទៅនិព្វាន ។

✍📖✍

# ៧២.ថាមិនមែនរូបដដែលទេ!

៙❀៙

ಌ ថ្ងៃខែចេះតែកន្លងទៅ

រូបកាយមិននៅក្មេងទៀតឡើយ

សាច់ជ្រួញធ្មេញបាក់សក់ស្កូវហើយ

រោគក៏មិនស្បើយកើតដេរដាស ។

ಌ បើគិតមិនដល់យល់ច្រឡំ

ថាតូចទៅធំក្មេងទៅចាស់

ជារូបតែមួយគ្មានប្តូរផ្លាស់

តាមពិតព្រះត្រាស់ធម៌សច្ចៈ ។

ಌ ថារូបកើតស្លាប់បន្តគ្នា

ផ្លាស់ប្តូរគ្រប់គ្រាលឿនឥតអាក់

ភ្នែកគ្មានបញ្ញាប្រៀបដូចខ្វាក់

មិនឃើញសច្ចៈធម៌អនិច្ចំ ។

ಌ ស្លាប់កើតទាំងរស់រាប់ពុំបាន

តែមិននឹកស្មានថាមានខ្វាំង

គឺអវិជ្ជាមករាំងបាំង
បិទទាំងអនិច្ចំអនត្តា ។
៙ រូបច្រើនឲ្យឃើញរូបតែម្នាក់
រស់តពីថ្នាក់នៅកូនង៉ា
រហូតដល់បានឈ្មោះយាយតា
ក៏នៅតែថារូបដដែល ។

## ៧៣.ព្រះនាងរោហិណីសរសើរគុណព្រះសង្ឃ

៙ ព្រះនាងរោហិណី បានស្រដីរៀបរាប់ថា
បពិត្រលោកបិតា កូនជ្រះថ្លានឹងព្រះសង្ឃ ។
៙ សមណៈធ្វើការងារ គ្រប់វេលាដោយផ្ចិតផ្ចង់
បដិបត្តិតាមផ្លូវត្រង់ កម្ចាត់បង់នូវឫសគល់ ។
៙ នៃរាគៈទោសៈ លោភមោហៈជាពិសពុល
នាំសត្វឲ្យងប់ងល់ នៅវិលវល់ក្នុងលោកិយ ។

៙ សមណៈមិនប្រមាទ ធ្វើកម្មស្អាតគ្រប់ទាំងបី
មនោកាយវចី ស្អាតប្រក្រតីទាំងក្រៅក្នុង ។
៙ សមណៈជាពហុស្សូត ព្រះទ័យស្លូតតែងទ្រទ្រង់
នូវធម៌ជាអរិយវង្ស ពង្សព្រះពុទ្ធបរិសុទ្ធក្រៃ ។
៙ មានអារម្មណ៍តែមួយ រស់គ្មានព្រួយដោយស្មារតី
លោកតែងសម្ដែងន័យ អត្ថធម៌ថ្លៃឲ្យយល់ងាយ ។
៙ សមណៈនៅដោយធម៌ ចិត្តខ្ពស់ល្អឥតរាយមាយ
ទោះក្នុងទីជិតឆ្ងាយ តែងពោលស្រាយដោយប្រាជ្ញា ។
៙ ពេលផ្លាស់ទីគង់នៅ លោកចេញទៅតែអាត្មា
ប្រៀបដូចសត្វបក្សា ចរយាត្រាគ្មានអាល័យ ។
៙ គ្មានទ្រព្យព្រួយលាក់ទុក គ្មានជង្រុកស្រូវសាលី
គ្មានឆ្នាំងកញ្ជើរល្អី ព្រមអាស្រ័យតែភោជន៍ស្រេច។
៙ សមណៈមិនប្រាថ្នា មាសប្រាក់ណាទោះប៉ុនខ្សាច់
អនុគ្រោះជាចាំបាច់ ទទួលតែវត្ថុម្យ៉ាង ។
៙ ដែលកើតចំពោះមុខ ផ្ដល់ភាពសុខទាំងសងខាង
ដើម្បីគ្រាន់តែញ៉ាំង អត្តភាពឲ្យប្រព្រឹត្តទៅ ។

៚ សមណៈចេញអំពី គ្រប់ទិសទីមករស់នៅ
ក្នុងផ្ទះសប្បុរសរួមផ្លូវ តែងរាប់គ្នាដោយស្មោះស្ម័គ្រ។
៚ បពិត្រលោកបិតា កូនជ្រះថ្លានឹងសមណៈ
ព្រោះហេតុទាំងនោះជាក់ កូនមិនលាក់ពោលតាមត្រង់។
៚ ពេលនោះឪពុកនាង បានស្តាប់ផ្ទៀងគុណព្រះសង្ឃ
ជឿរពិតថាផូរផង់ ល្អត្រចង់លើសអ្វីៗ ។
៚ ទើបពោលសរសើរថា ម្នាលធីតាពោហិណី
នាងកើតជាស្ត្រី ក្នុងត្រកូលនៃពួកយើង ។
៚ ដើម្បីប្រយោជន៍ពិត មានគំនិតខ្ពស់ថ្កុំថ្កើង
សទ្ធាធំដូចភ្លើង ដុតរំលើងអនុស័យ ។
៚ នាងស្គាល់ស្រែបុណ្យធំ គុណឧត្តមគឺរតន៍ត្រៃ
ព្រះពុទ្ធធម៌សង្ឃថ្លៃ ដែលគ្មានអ្វីប្រៀបផ្ទឹមបាន ។
៚ កូនស្រីពោលទៀតថា បើបិតាខ្លាចរំខាន
ដោយទុក្ខរុកទន្ទ្រាន ចិត្តសន្តានរាល់វេលា ។
៚ ចូរដល់នូវព្រះពុទ្ធ ដ៏ជាមកុដផុតសួគ៌ា
ដល់នូវព្រះធម៌ជា ម្លប់រួមគ្នាព្រះសង្ឃផង ។

✍ ព្រមទាំងសមាទាន សីលជាស្ពានធំកន្លង
នឹងបានជារបង ជាទីពឹងលុះអមតៈ ។
✍ បិតាស្លាប់កូនហើយ មិនឃ្លូរទ្បើយព្រមស្មោះស្ម័គ្រ
សង្វេគក្នុងចិត្តជាក់ សូមបួសស្នាក់ជាបព្វជិត ។
✍ ចម្រើនវិបស្សនា លះមោហាភាពងងឹត
ក៏បានពាល់ត្រូវពិត ទីប្រណីតព្រះនិព្វាន ។

✍📖✍

## ៧៤. អ្នកសូមទានមិនមែនជាភិក្ខុទេ

✍ បុគ្គលដើរសូមជនទាំងឡាយ
ក្នុងទីជិតឆ្ងាយដោយហេតុណា
អ្នកនោះមិនទាន់បានឈ្មោះថា
ភិក្ខុដោយហេតុត្រឹមនោះទេ ។
✍ បុគ្គលសមាទានធម៌អាក្រក់
មានចិត្តកខ្វក់ល្អក់វៀចវេរ

មិនបានឈ្មោះជាភិក្ខុទេ
លុះតែជនណាក្នុងលោកនេះ ។
✍ បន្សាត់បុណ្យបាបអស់ពីចិត្ត
ប្រព្រឹត្តសុចរិតឥតមានធ្វេស
ត្រាច់ទៅក្នុងលោកជាអ្នកចេះ
ទើបបុគ្គលនោះឈ្មោះភិក្ខុ ។

✍📖✍

## ៧៥.អកុសលចិត្តខ្លះត្រូវផ្ចាញ់ដោយវិធីណា?

✍ បុគ្គលគប្បី យកធម៌ខន្តី
ផ្ចាញ់មនុស្សដែលក្រោធ កាលខឹងក្តៅឆេះ
ចេះទៅជាឆោត ផ្ចាញ់ដោយមិនក្រោធ
ឈ្មោះគ្រប់បញ្ញា ។
✍ រីអសប្បុរស មិនមានចិត្តស្មោះ

ទទួលធម៌អាថ  គួរផ្ចាញ់ដោយចិត្ត
អាណិតមេត្តា  ទាំងកាយវាចា
តបដោយភាពល្អ ។

៙ ឯមនុស្សកំណាញ់  បុគ្គលគួរផ្ចាញ់
យកឈ្នះចិត្តក្រ  ដោយឲ្យទានញឹក
ល្ងាចព្រឹកបន្ត  មច្ឆរិយៈក៏
គង់តែមរណា ។

៙ រីមនុស្សកុហក់  ពោលពាក្យអាក្រក់
ឡេះឡោះមុសា  គួរផ្ចាញ់ដោយពាក្យ
ពិតមានខ្លឹមសារ  សច្ចវាចា
ឈ្នះរសទាំងពួង ។

✍📖✍

# ៧៦.គួរគ្រាប់អ្នកប្រាជ្ញ

៙ ជនទាំងឡាយណាជាអ្នកប្រាជ្ញ
សន្ដោសមិនកាចបៀតបៀនសត្វ
ព្យាយាមសង្រួមប្រុងប្រយ័ត្ន
ចិត្តកាយអណ្ដាតរាល់វេលា ។
៙ ជនទាំងឡាយនោះរមែងទៅ
កាន់ស្ថានដែលនៅហួសសួគ៌ា
ជាស្ថានអមតៈជនគ្រប់គ្នា
ស្គាល់ហើយធានាមិនសោកស្ដាយ ។

# ៧៧.ព្រះពុទ្ធោវាទចំពោះភ្នូនគោឃាតកៈ

៙ ឥឡូវខ្លួនអ្នកប្រែគ្រប់អន្លើ
ប្រៀបដូចស្លឹកឈើទុំជិតជ្រុះហើយ
ស្បៀងគឺកុសលក៏មិនមានឡើយ
ចូរកុំកន្ដើយឆាប់រកទីពឹង ។

៙ ទាំងពួកបុរសរបស់យមរាជ

ពេញដោយអំណាចគ្មានអ្វីទទឹង

នាំយកអ្នកទៅមិនអាចមុខរឹង

ប្រកែកខំប្រឹងអង្វរពន្យា ។

៙ ឥឡូវអ្នកនៅក្នុងក្តីវិនាស

ត្រូវស្រូតរវាសធ្វើបុណ្យនានា

ព្រោះអ្នកកំពុងតែត្រូវជរា

កៀងចូលមាត់នៃដែនមរណៈ ។

៙ ចូរអ្នកព្យាយាមឲ្យឆាប់កុំខ្លាច

ចូរជាអ្នកប្រាជ្ញរួចពីវដ្តៈ

រួចជាតិជរាព្យាធិមរណៈ

ភូមិព្រះអរិយៈទទួលអ្នកបាន ។

៙ ពេលអ្នកលែងមានទួលគឺកិលេស

បាបចាញ់ចំណេះឈប់ហ៊ានរំខាន

ពីព្រោះមន្ទិលក្នុងចិត្តប៉ុន្មាន

អ្នកលះរុញច្រានលាងបានល្អហើយ ។

# ៧៨.ព្រះពុទ្ធោវាទប្រារព្ធនូវកុលបុត្រទូទៅ

៙ ផិតក្បត់ភស្តាប្រព្រឹត្តអាក្រក់
ជាធម៌កខ្វក់នាំធ្លាក់អវចី
និងជាមន្ទិលរបស់ស្ត្រី
ដឹងហើយកុំបីមានក្តីប្រមាទ ។
៙ រីភាពកំណាញ់ក៏ជាមន្ទិល
នៃជនល្ងង់ខ្ជិលមិនប្រឹងសង្វាត
ធ្វើបុណ្យធ្វើទានសន្សំចិត្តឆ្លាត
ខ្លាចអស់ខ្លាចខាតព្រោះមច្ឆរិយៈ ។
៙ ចំណែកឯធម៌អាក្រក់ទាំងឡាយ
ដែលយើងខ្វល់ខ្វាយទទួលរាក់ទាក់
ក៏ជាមន្ទិលក្នុងលោកនេះជាក់
ព្រមទាំងបរលោកឯនាយផង ។
៙ ប៉ុន្តែធម្មជាតិដែលជាមន្ទិល
នាំយើងឲ្យវិលជាប់ក្នុងចំណង

គឺអវិជ្ជាជាគ្រឿងសៅហ្មង

លើសលប់ចំបងជាងអ្វីទាំងអស់ ។

✍ ភិក្ខុទាំងឡាយចូរអ្នកលះចេញ

មន្ទិលនោះមិញកុំស្ដាយស្រណោះ

កុំជាអ្នកមានមន្ទិលសោះ

នេះហើយផ្លូវរស់នៃពុទ្ធសាសនា ។

✍📖✍

## ៧៩.ព្រះពុទ្ធោវាទប្រារព្ធនូវមេណ្ឌកសេដ្ឋី

✍ ទោសរបស់ពួកជនដទៃ

រវាសរវៃមើលឃើញភ្លាម

ឯទោសខ្លួនឯងតែងព្យាយាម

បិទបាំងលាក់លៀមពុំមានស្រាក ។

✍ ទោសគេឆាប់ឃើញហួសប្រមាណ

ទោសខ្លួនឃើញបានដោយលំបាក

ព្រោះចិត្តបុគ្គលនោះតោកយ៉ាក

រោយទោសប្រទូឡាក់អ្នកដទៃ ។

✍ ប្រៀបដូចបុគ្គលរោយអង្កាម

ហើយបិទបាំងស្នាមជាប្រក្រតី

លាក់ទោសខ្លួនដូចព្រានបក្សី

ពេលចង់ប្រល័យសត្វនានា ។

✍ គេតុបតែងខ្លួនគ្រប់អន្លើ

បាំងដោយមែកឈើធ្វើដូចជា

មិនមែនជាព្រានមានចិត្តមារ

ចាំប្រុងប្រហារសត្វនោះឡើយ ។

## ៨០.ឈ្មោះនៃកុសលធម៌

✍ កុសលជាឈ្មោះនៃធម៌មួយ

គ្រប់ពេលចាំជួយសម្អាតចិត្ត

លាងអស់ទាំងបាបធំតូចល្អិត

ដែលពួកបណ្ឌិតតែងតិះដៀល ។

# ៨១.កុំចង់កែ

បុណ្យបាបនៃសត្វមនុស្ស កើតឡើងស្មោះព្រោះអាស្រ័យ
គ្រប់គ្រាន់ហេតុបច្ច័យ នឹកឃើញអ្វីរៃរជាយល់ ។
ថាខ្លួនជាអ្នកធ្វើ គ្រប់អំពើបុណ្យកុសល
ចុះធម៌អកុសល ឥតអ្នកផ្ដល់ម្ដេចកើតដែរ? ។
តាមពិតមកពីហេតុ ច្បាស់ក្រៃឡែតគ្មានប្រួលប្រែ
ធម៌ដែលកើតហូរហែរ កុំចង់កែថាយើងធ្វើ ។

# ៨២.ខុសគ្នាជានិច្ច

កុំចង់ឲ្យចិត្តគេដូចចិត្តយើង
សូម្បីចិត្តយើងក៏មិនដូចគេ
ព្រោះការកសាងមកពីបុព្វេ
ទាំងយើងទាំងគេខុសគ្នាជានិច្ច ។

# ៨៣.បណ្ដាំម្ដាយ

៙ គ្មានអ្វីអាចប្ដូររូបកូនទាំងឡាយ
ចេញពីចិត្តម្ដាយដែលស្រឡាញ់ថ្លៃ
ក្រៅពីមច្ចុនិងហេតុបច្ច័យ
លើភពផែនដីគ្មានអ្វីជួសបាន ។
៙ ចំណែកផលកម្មចាំកត់ជានិច្ច
កូនខុសច្រើនតិចគ្មានដែលខកខាន
បើម្ដាយវិញតែងសន្ដោសប្រោសប្រាណ
តែកម្មមិនបានអត់ទោសកូនទេ ។
៙ ច្នេះត្រូវព្យាយាមធ្វើបុណ្យប្រចាំ
រក្សាសីលប្រាំជាប់កុំទំនេរ
បានកើតជាមនុស្សកុំឲ្យទុក្ខគេ
ចិត្តយើងចិត្តគេខ្លាចទុក្ខដូចគ្នា ! ។

# ៨៤.កុំចង់ចំណេញ

ꕥ

✍ ឈប់ចង់បានអ្វីពីលោកនេះទៅ

ព្រោះសុទ្ធជាផ្លូវនៃការប្រមាទ

សង្រួមស្តាប់ធម៌ទើបចិត្តល្អស្អាត

បើមិនចង់ខាតកុំចង់ចំណេញ ។

✍📖✍

# ៨៥.ទោសនៃលោភៈទោសៈមោហៈ

ꕥ

នៅពេលលោភៈ នាំជាប់ជំពាក់ ត្រេកអរចង់បាន

វង្វេងភ្លេចគិត ឃាត់ចិត្តឃាត់ប្រាណ ច្រឡំនឹកស្មាន

ថាបានហើយគ្រប់ ។

ប៉ុន្តែភាពល្មោភ នៅក្នុងចិត្តលោភ ប្រាថ្នាឥតឈប់

កាន់តែបានច្រើន កាន់តែមិនគ្រប់ បើមិនប្រឹងទប់

ងប់ធ្លាក់អបាយ ។

រីឯទោសៈ បើធ្លាប់អន់អាក់ ខឹងក្តៅក្រហាយ
ពីតូចទៅធំ នឹងនាំអន្តរាយ ត្រូវឆាប់ដោះស្រាយ
ដោយធម៌ខន្តី ។

គួរពិចារណា កាលព្រះសាស្តា ត្រូវស្តេចអប្រិយ
កាត់ស្លឹកត្រចៀក ច្រមុះជើងដៃ ទ្រង់ឈឺខ្លាំងក្រៃ
គង់នៅទ្រាំបាន ។

កាលរៀបអស់ជន្ម ព្រះទ័យអត់ធន់ ទោះឈាមជោគប្រាណ
អភ័យសន្តោស ប្រោសមនុស្សសាមាន្យ តែធរណីបាន
ស្រូបស្តេចនោះហើយ ។

ចំណែកមោហៈ មានភ្នែកដូចខ្វាក់ មិនយល់កោះត្រើយ
កើតទាន់សាសនា ព្រះពុទ្ធបង្កើយ តែធ្វើព្រងើយ
ដូចមនុស្សឥតភ័ព្វ ។

ពេលដើរជួបមាស អ្នកខ្លះរវាស រើសទុកជាទ្រព្យ
យល់ថាល្អពិត ប្រណីតគួរគាប់ សឹងថាពេលងាប់
យកជាប់ទៅផង ។

តែអ្នកខ្លះទៀត មោហៈជ្រែកជ្រៀត ខំរើសកោងខ្នង
តែសម្បកផ្ទៃ អររំភើកន្លង រែកផងទូលផង
ប៉ងធ្វើអ្នកមាន ។

# ៨៦.គុណនៃសតិប្បដ្ឋាន

គ្មានសត្វបុគ្គលដល់ម្នាក់សោះ
អាចនឹងឈរឈ្មោះធ្វើវេទនា
តាមពិតក្តីទុក្ខឬសុខជា
សុទ្ធតែធម្មាគ្មានតួខ្លួន ។

ពេលខ្លះសុខកាយសប្បាយចិត្ត
រួចទុក្ខដេញស្អិតកិតកើតផ្ទួន
បើរលឹកដល់សតិប្បដ្ឋាន៤
ទើបចិត្តមាំមួនរកឃើញផ្លូវ ។

ឈ្មោះអវិជ្ជាភាពមិនដឹង
ធ្លាប់យល់ខុសម្លឹងប្រឹងរកត្រូវ

ស្ដាប់ធម៌ព្រះពុទ្ធពីឥឡូវ

ទោះម្ទៃស្លាប់ទៅក៏ប្រសើរ ។

## ៨៧.ព្រហ្មចរិយធម៌ជាថ្នាំ

ការស្វែងរកកាមដូចជនខ្លៅ

ដើរហាលថ្ងៃក្ដៅហើយស្រេកទឹក

ពេលជួបប្រទះដូចបានផឹក

អំបិលលាយទឹករឹតស្រេកខ្លាំង ។

ដូច្នេះវិធីចេញចាកកាម

មានតែឃាត់ហាមទប់ទល់ខ្នាំង

ប្រព្រឹត្តព្រហ្មចរិយតតាំង

ទើបឈ្នះកម្លាំងកិលេសបាន ។

# ៨៨.ផែនដីមិនលំអៀង

៙ ទឹកដូងទឹកត្នោតទឹកអំពៅ
រសផ្អែមជាប់នៅនឹកជានិច្ច
តែស្តៅក្រូចឆ្មាបណ្តូលពេជ្រ
ជូរល្វីងប្រឹងធ្មេចទើបលេបបាន ។
៙ រសខុសគ្នានេះមកពីអ្វី
ឬមួយផែនដីប្រែសាមាន្យ
ផ្តល់ភាពល្វីងជូរផ្អែមប៉ុន្មាន
តាមដីរាប់អានសន្តានញាតិ? ។
៙ ការពិតរសផ្អែមល្វីងជូរចត់
តែងមានប្រាកដពីធម្មជាតិ
ធរណីមិនអាចធ្វើឲ្យឃ្លាត
ខុសឆ្ងាយពីធាតុធ្លាប់ប្រក្រតី ។
៙ គួរប្រៀបសម្លេងរូបក្លិនរស
ធម្មៈសម្ផស្សនឹងផែនដី

ឯចិត្តឃើញឮចិត្តដឹងអ្វី
ត្រឹមជាបច្ច័យកម្មប៉ុណ្ណោះ ។

៚ មេបុណ្យមេបាបកើតមានពិត
តែនៅក្នុងចិត្តយើងស្រីប្រុស
គ្មានអ្នកដ៏ទៃមកបណ្តុះ
បញ្ចូលបញ្ចុះខុសហេតុឡើយ ។

៚ បើបានស្តាប់ធម៌បានសិក្សា
មានមនសិការៈបង្កើយ
ជាយោនិសោលាងចិត្តឲ្យ
អស់បាបបានស្បើយពីក្តីទុក្ខ ។

## ៨៩.ស្តាយពុកណាស់

៚ អ្នកម៉ែនិងកូនសែនស្តាយពុក
ពីនេះទៅមុខយើងបាត់បង់
បាត់ទាំងឱវាទចិត្តផ្ទូរផង់
បាត់គ្រូចំបងក្នុងជីវិត ។

✍ កូនៗឱនកាយថ្វាយបង្គំ
សពពុកហើយយំដោយភ្លេចគិត
ភ្លេចថានេះហើយជារឿងពិត
តែមានជីវិតគេចមិនបាន ។

✍ បើកូនធ្វើខុសប្រការណា
សូមលោកមេត្តាជួយប្រោសប្រាណ
ប្រណីអត់ទោសឲ្យកូនបាន
ក្ដីសុខក្សេមក្សាន្តដូចប្រាថ្នា ។

✍ ពុកតែងប្រាប់កូនឲ្យធ្វើល្អ
ជាកិច្ចដំណាក្នុងគ្រួសារ
កូនៗប្រតិបត្តិតាមមាត្រា
សូមពុកថ្លៃថ្លាស្ងប់ចិត្តចុះ ។

✍📖✍

# ៩០.ព្រៃគោសិង្គសាលវ័នរុងរឿង ដោយសារភិក្ខុណា?

ពេលមួយក្នុងព្រៃគោសិង្គៈ
មានព្រះកស្សបះព្រះអនុរុទ្ធ
ព្រះមោគ្គលានព្រះសារីបុត្ត
ជាសាវ័កពុទ្ធឆ្លាតប្រពៃ ។

ទាំងព្រះអានន្ទពុទ្ធុប្បដ្ឋាក
ថែមព្រះរេវតៈព្រះនាមល្បី
កំពូលថេរៈមានគុណក្រៃ
នាំគ្នាឃ្មាតខ្មីថ្វាយបង្គំ ។

ព្រះមានព្រះភាគក្រាបទូលថា
ពួកខ្ញុំព្រះករុណាបានប្រជុំ
ព្យាករបដិភាណតាមសមរម្យ
រៀងខ្លួនដោយពុំហ៊ានមុសា ។

៚ ខ្ញុំសារីបុត្តសួរអានន្ទ
ថាព្រៃសាលវន័គួរជ្រះថ្លា
ដើមឈើទាំងឡាយក៏មានផ្កា
ចម្រុះល្អស្រស់រីកស្គុះស្គាយ ។
៚ ក្រអូបឈ្ងុយឈ្ងប់សព្វកន្លែង
គួរនាដូចក្លិនទិព្វផ្សព្វផ្សាយ
រាត្រីសោតក៏គួររីករាយ
ពពកឃ្លាតឆ្ងាយមេឃស្រឡះ ។
៚ គ្មានទឹកសន្សើមគ្មានផ្សែងអ័ព្ទ
គ្មានរាហូចាប់ដីហុយប៉ះ
អានន្ទចូរអ្នកឆ្លើយប្រកាស
ព្រៃគោរុងរឿងដោយភិក្ខុណា ។
៚ ព្រះអានន្ទតបក្នុងសាសនានេះ
ភិក្ខុចាំចេះពុទ្ធវចនា
ទ្រទ្រង់សន្សំព្រះដីកា
ធម៌ទាំងឡាយណាមានលំអ ។

៙ បទដើមកណ្តាលនិងបទចុង
គ្រប់ព្យញ្ជនៈក្នុងវេយ្យាករណ៍
ប្រកាសនូវព្រហ្មចរិយៈដ៏
បរិសុទ្ធប-រិបូណ៌ទាំងអស់ ។
៙ ធម៌ទាំងឡាយមានភាពដូច្នេះ
ភិក្ខុនោះចេះគ្មានចន្លោះ
ជំនាញរត់មាត់ស្ទាត់ឥតខ្ចោះ
ស្ម័គ្រស្មោះពិចារណាដោយចិត្ត ។
៙ ភិក្ខុនោះតែងសម្តែងធម៌
ដល់បរិស័ទល្អប្អូនពួកពិត
ដោយបទនិងព្យញ្ជនៈលម្អិត
ជាបរិមណ្ឌលជាប់តគ្នា ។
៙ ដើម្បីជួយដាស់គាស់រំលើង
នូវអនុស័យគ្រប់វេលា
ព្រៃគោរុងរឿងបានដោយសារ
ភិក្ខុនេះណាសារីបុត្ត ។

๛ រួចខ្ញុំព្រះអង្គសួរបន្ត
 រេវតៈឆ្លើយតគ្មានតក់ស្លុត
ម្នាលអាវុសោសារីបុត្ត
 ភិក្ខុនៅក្នុងពុទ្ធសាសនា ។
๛ ត្រេកអររីករាយពួនសម្ងំ
 រឿយៗអប់រំនូវបញ្ញា
ស្ងប់ស្ងាត់ចិត្តដោយវិបស្សនា
 ចម្រើនសុញ្ញាគារធម៌ ។
๛ ព្យាយាមប្រព្រឹត្តក្នុងសន្តាន
 មិនប្រាសចាកឈានថ្លៃបវរ
ព្រៃគោសាលវ័នមានលំអ
 រុងរឿងដោយសារភិក្ខុនោះ ។
๛ រួចខ្ញុំព្រះអង្គសួរអនុរុទ្ធ
 ប្រាជ្ញាស្រួចមុតឆ្លើយពីរោះ
ក្នុងពុទ្ធសាសនាដ៏ខ្ពង់ខ្ពស់
 ភិក្ខុមើលឃើញនូវលោកធាតុ ។

៙ មួយពាន់ដោយភ្នែកបរិសុទ្ធថ្លា
ដូចទិព្វចក្ខុប្រសើរស្អាត
កន្លងហួសភ្នែកមនុស្សគ្រប់ជាតិ
ប្រៀបដូចបុរសនៅខាងលើ ។
៙ ក្រឡេកឃើញមណ្ឌលនៃខ្នងកង់
មួយពាន់ច្បាស់ត្រង់គ្រប់អន្លើ
មើលពីប្រាសាទដ៏ប្រសើរ
ព្រៃគោរុងរឿងបានដោយសារ ។
៙ ភិក្ខុនោះឯងជាលំអ
ខ្ញុំព្រះអង្គបន្តសាកច្នា
សួរមហាកស្សបៈដ៏ថ្លៃថ្លា
លោកក៏ឆ្លើយថាសាសនាព្រះ ។
៙ ពុទ្ធអង្គមានសង្ឃអ្នកនៅព្រៃ
សសើរគុណនៃអ្នកបានលះ
មិនជាប់ជំពាក់ញាតិទ្រព្យផ្ទះ
ចិត្តផុតស្រឡះអស់សៅហ្មង ។

៚ ភិក្ខុនោះឯងតែងប្រព្រឹត្ត
បិណ្ឌបាត្រឆ្ងាយជិតទាំងទ្រទ្រង់
សំពត់បង្សុកូលខ្លួនឯងផង
សរសើរកន្លងលោកផងគ្នា ។
៚ ភិក្ខុទ្រទ្រង់ត្រឹមតែបី
នូវចីវរត្រៃដែលត្រូវការ
ជាអ្នកមិនមានក្តីប្រាថ្នា
សន្តោសខ្លាំងក្លាដោយសុទ្ធចិត្ត ។
៚ ជាអ្នកស្ងប់ស្ងាត់មិនច្រឡូក
ច្រឡំផ្សំបូកនិងញាតិមិត្ត
ប្រុងប្រៀបព្យាយាមខ្លួនឯងពិត
សំអាតផ្លូវចិត្តពុំមានខ្ជិល ។
៚ ជាអ្នកបរិបូណ៌ដោយបញ្ញា
ច្រើនទាំងសម្មាធិនិងសីល
ព្រមដោយវិមុត្តិឥតរល់រិល
រួចផុតមន្ទិលចូលដល់ថ្នាក់ ។

៚ ជាអ្នកបរិបូណ៌បរិសុទ្ធ
ល្អដោយវិមុត្តិញាណទស្សនៈ
បានសសើរគុណដោយស្មោះស្ម័គ្រ
លោកអ្នកទ្រទ្រង់គុណដូចគ្នា ។
៚ ព្រៃគោរុងរឿងភ្លឺត្រចះ
ដូចមេឃស្រឡះមានចន្ទ្រា
ក៏ដោយភិក្ខុរូបនេះណា
សារីបុត្តមេត្តាជ្រាបសេចក្តី ។
៚ តមកដល់វេនមហាមោគ្គលាន
ព្យាករបដិភាណដោយប្រពៃ
លោកមានអាយុបាននិយាយ
ថាម្នាលសារីបុត្តថ្លៃថ្លា ។
៚ ភិក្ខុពីររូបឈ្លាសមុតមាំ
សំដែងអភិធម្មកថា
សាកសួរហើយដោះស្រាយប្រស្នា
ដល់គ្នានិងគ្នាឥតសៅហ្មង ។

❧ កថារបស់ភិក្ខុនោះ

ប្រព្រឹត្តទៅស្មោះដោយធម៌ផង

មិនបានរុករានគ្នាលោកផង

សុខស្ងប់កន្លងធម្មសប្បាយ ។

❧ ម្នាលអាវុសោសារីបុត្ត

ព្រៃគោល្អផុតនឹងបរិយាយ

រុងរឿងដោយភិក្ខុទាំងឡាយ

សាកសួរដោះស្រាយប្រស្នាធម៌ ។

❧ រួចព្រះមោគ្គលានក្រាបបង្គំ

ទូលម្ចាស់ឧត្តម[១]ជាបន្ត

ថាយើងរាល់គ្នាបានព្យាករ

បដិភាណសមល្អដល់ខ្លួនហើយ ។

❧ ឥឡូវសូមសួរសារីបុត្ត

ចុងគេបំផុតមេត្តាឆ្លើយ

(១) *ម្ចាស់ឧត្តមគឺព្រះសម្មាសម្ពុទ្ធ*

ព្រះសារីបុត្តមិនកន្តើយ

ឆ្លើយប្រាប់ពួកយើងយ៉ាងនេះថា ។

๛ ម្នាលអាវុសោមោគ្គលាន

ភិក្ខុដែលមានក្នុងសាសនា

ព្រះមានព្រះភាគដ៏ថ្លៃថ្លា

បញ្ជាផ្តាច់ការទៅលើចិត្ត ។

๛ ឲ្យធ្វើតែក្នុងអំណាចខ្លួន

ប្តេជ្ញាមាំមួនមិនប្រព្រឹត្ត

មិនលុះទៅតាមអំណាចចិត្ត

រួចផុតចាកពិតកាមាសវៈ ។

๛ បើភិក្ខុនោះប្រាថ្នាដើម្បី

នៅអស់សម័យបុព្វណ្ហៈ

ឬនៅអស់មជ្ឈន្តិកៈ

អស់សាយណ្ហៈក៏នៅបាន ។

๛ សុខដោយវិហារសមាបត្តិ

ប្រៀបដូចមហាមាត្រនិងក្សត្រក្សាន្ត

ទ្រទ្រង់សំពត់គូប៉ុន្មាន

ក៏អាចនៅបានគ្រប់វេលា ។

๛ ព្រៃគោសិង្គសាលវ័ន[២]

រុងរឿងសោភ័ណក៏ដោយសារ

ភិក្ខុដែលបានតាំងប្តេជ្ញា

ប្រើបញ្ញាការទៅលើចិត្ត ។

๛ ពេលនោះសម្តេចព្រះទ្រង់ញាណ

សសើរបដិភាណខ្ពស់ប្រណីត

ដែលគ្រប់សាវ័កទូលលំអិត

ព្យាករត្រូវពិតគួរជ្រះថ្លា។

๛ រួចហើយព្រះសារីបុត្តផ្គុំ

ហត្ថក្រាបបង្គំព្រះសាស្តា

សូមព្រះរាជទានប្រោសមេត្តា

តើលោកអង្គណានិយាយត្រូវ? ។

---

*(២) សូមអានថា ព្រៃគោសិង្គៈសាលៈវ័ន*

៚ ស្តេចទ្រង់ត្រាស់ថាសារីបុត្ត
ទាំងអស់គ្នាសុទ្ធតែត្រឹមត្រូវ
អាចញុាំងព្រៃគោរុងរឿងទៅ
តែអ្នកទាំងឡាយចូរចាំស្តាប់។
៚ ភិក្ខុនៅក្នុងសាសនានេះ
ឆាន់ហើយត្រិះរិះស្រូតប្រញាប់
អង្គុយពែនភ្នែនតាមទំលាប់
ឆាប់ពត់កាយត្រង់ផ្ចង់ស្មារតី។
៚ ឲ្យត្រង់ទៅមុខដោយគិតថា
បើចិត្តអាត្មានៅអាល័យ
នៅប្រកាន់ជាប់ទ្រព្យលោកិយ
មិនរួចពីភ័យគឺអាសវៈ។
៚ ទេនោះអញនឹងមិនទំលាយ
ភ្នែនចេញងាយៗនាំអាក់
ទីព្រៃសាលវ័នគោសិង្គៈ
រុងរឿងដោយសារភិក្ខុនោះ។

✍ គ្រប់អង្គស្តាប់ចប់ពុទ្ធភាសិត
ត្រេកអរពេញចិត្តដោយចំពោះ
ព្រះសូរសៀងថ្លៃសែនពីរោះ
សម្តេចទ្រង់យសប្រោសប្រទាន។

✍📖✍

# ៩១.ន័យនៃការបាចលាច

✍ រូបយើងរាល់គ្នាមិនទៀងទាត់
កើតហើយស្លាប់ព្រាត់ព្រោះអនត្តា
ទៅតាមនិយាមកម្មធម្មតា
ដែលយើងប្រាថ្នាចៀសឲ្យផុត ។
✍ ស្លាប់ត្រឹមតែម្នាក់ក៏ច្រើនហើយ
រាប់មិនអស់ឡើយកើតរួចច្យុត
សែនលានកោដិដងគួរតក់ស្លុត
បើមិនបានដុតនៅសល់ធាតុ ។

✍ បាក់បែកតូចធំឬវែងខ្លី

ពាសពេញផែនដីសព្រោងព្រាត

ខ្លះកប់ជាន់គ្នាជាច្រើនទៀត

សូមផ្ដាំញោមញាតិកុំប្រមាទ ។

✍ លាចសប្រៀបដូចឆ្អឹងរាត់រាយ

បើមិនរលាយឃើញគ្រប់ខ្នាត

ចោលពាសពេញដីចំណើត្អាត

អ្នកប្រាជ្ញវៃឆ្លាតឲ្យប្រស្នា ។

✍ ច្នេះត្រូវលះបាបចំរើនបុណ្យ

គួរសាធុជនស្ដាប់ធម៌អាថ៌

បំព្រួញឲ្យខ្លីវដ្តសង្សារ

ត្រាស់ដឹងកាលណាចប់ទុក្ខហោង ។

✍📖✍

# ៩២.គុណមាតាបិតា

៙ កាលកូននៅតូចម៉ែបីបម

ចិញ្ចឹមថ្នាក់ថ្នមដោយករុណា

ផ្លូតទឹកបញ្ចុកម្ហូបអាហារ

កូនឈឺពេលណាម៉ែលំបាក ។

៙ ពុករត់រកពេទ្យទាំងភ័យព្រួយ

រីម៉ែបីស្ទួយកូនគ្មានស្រាក

ភ្លេចគិតខ្លួនឈឺម៉ែបរិច្ចាគ

លះពេលសំរាកព្រោះមេត្តា ។

៙ សរុបតាំងពីកូនចាប់ផ្ទៃ

លុះកើតដឹងក្តីធំកាលណា

ពុកម៉ែបង្រៀនសព្វកិច្ចការ

រួចឲ្យសិក្សាតាមជាន់ថ្នាក់ ។

៙ ម៉ែពុកជាព្រហ្មជាទេវតា

ជាបុព្វាចារ្យអាហុនេយ្យៈ

រងបាបជួសកូនដោយស្មោះស្ម័គ្រ
លើលោកគ្មានអ្នកណាស្មើបាន ។
៚ ទោះយកសម្បត្តិស្តេចចក្រពត្រ
មកដូរពង្រាត់កូនកល្យាណ
ពីពុកម៉ែទៅពិតជាខាន
ម៉ែមិនសុខសាន្តប្តូរកូនឡើយ ។
៚ ចាប់ពីពេលនេះតទៅមុខ
ទោះបីជាពុកមរណាហើយ
កូនគោរពម៉ែមិនកន្តើយ
សូមម្តាយបានស្បើយពីទុក្ខា ។
៚ ទោះយកផែនដីធ្វើក្រដាស
ភ្នំច្រើនក្រៃក្រាស់ធ្វើប៉ាកា
យកទឹកសមុទ្រមកឧបមា
សរសេរអក្ខរាចារពីគុណ ។
៚ លោកអ្នកទាំងពីរក៏មិនគ្រប់
កូនរស់ក្រោមម្លប់សុខពេកពន់

គុណពុកនិងម៉ែពិតជាធ្ងន់

ឈ្មោះថាអរហន្តត្រូវគ្មានខ្ចោះ ។

៦. កូនសូមខមាទោសអ្នកម្តាយ

លោកពុកនៅឆ្ងាយគួរស្រណោះ

កូនសូមជូនបុណ្យលោកទាំងអស់

សូមពុកម៉ែប្រោសអនុមោទនា ។